នោះដែរ ។

-បងម៉េង !មើលពួកស្ទាវៗកំពុងចាប់នារីម្នាក់នោះ !ឈប់ឡានភ្លាមទៅបង! យើងទៅជួយគ្នាផង ! (សាវ៉ាន់និយាយទៅកាន់នាយម៉េង ដែលកំពុងបើកឡានដល់កន្លែងកើតហេតុដោយចៃដន្យ) ។អ្នកទាំងពីរពន្លត់ម៉ាស៊ីនឡានដើម្បីពិនិត្យហេតុការណ៍។ ពេលនោះម៉េងក្រឡេកឃើញក្មួយម៉ូដែល និងម៉ូដែនរបស់គេ ស្ថិតនៅក្នុងក្រុមអាស្ទាវ គេក៏ចុះពីឡានយ៉ាងរហ័ស ដើរសំដៅទៅរកក្មួយគេទាំងពីរ ។ ចំណែកនាយសាវ៉ាន់ពេលបានឃើញនាងសូណេត និង ម្ដាយខ្លួនកំពុងត្រូវក្រុមអាស្ទាវប្រទាញប្រទង់យ៉ាងសាហាវឃោឃៅដូច្នោះក៏ស្ទុះទៅច្រានថ្លុលនាយរាមអស់ទំហឹង . នាយរាមដួលទ្រេតទៅម្ខាង បើកភ្នែកសំឡក់ចង់ស៊ីសាច់សាវ៉ាន់ទាំងរៅ ។ សាវ៉ាន់ហក់យ៉ាងរហ័សទៅចាប់ដៃអាខ្មៅ ដែលកាន់កាំភ្លើងភ្ជង់មីងទៀងនោះអោយបង្វែរមាត់កាណុងឡើងទៅលើ ។ អាខ្មៅប្រឹងរើពីដៃសាវ៉ាន់ និងយកជង្គង់វាអុកឡើងលើចំពោះសាវ៉ាន់ ១ទំហឹង





ធ្វើអោយសាវ៉ាន់ឈឺចាប់យ៉ាងខ្លាំង ក៏របូតដៃពីនាយខ្មៅ ហើយថែមត្រូវនាយរាមនិងនាយស៊ើព្រួតគ្នាវាយទាត់ធាក់យ៉ាងខ្លាំងថែមទៀតនាយខំប្រឹងទប់ទល់យ៉ាងក្លាហាន ។ កម្លាំងកាយរបស់សាវ៉ាន់ មិនសូវមានប៉ុន្មានទេ ប៉ុន្ដែមកបានកម្លាំងចិត្តខ្លាំងសម្បើមណាស់ព្រោះតស៊ូដើម្បីនាងសូណេតទោះបីស្លាប់ក៏គេមិនរាថយដែរ ។ នាយម៉េងឃើញសាវ៉ាន់ត្រូវពួកអាស្ទាវចោមវាយដូច្នោះក៏ស្ទុះមកជួយ ។ នាយខ្មៅបង្វែរកាំភ្លើងតម្រង់នាយម៉េងហើយក៏កេះកៃផ្ទូង ! គ្រាប់កាំភ្លើងរត់ទៅហែកជើងខោនាយម៉េង ១ចំអាមឆ្លូតដាច់សាច់កំភួនជើង១ដុំ.....ចេញឈាមក្រហមឆ្អៅឆ្អឿមរំសេវឡប់ ។ នាយម៉េងក៏ទន់ជង្គង់ដួលចុះទៅដី ។ ម៉ូដែល និងម៉ូដែន ឃើញអាខ្មៅបាញ់នាយម៉េងក៏រត់ចេញពីម៉ូតូមកជួយពូរបស់គេ ។ ម៉ូដែលស្ទុះទៅដណ្ដើមកាំភ្លើងពីអាខ្មៅនិងស្រែកថា ៖

-អាខ្មៅកុំបាញ់ ! ពូអញទេ ! អោយកាំភ្លើងមកអញវិញ !

-អញមិនអោយទេ ! (អាខ្មៅតំហកតបវិញ) អាណាក៏ដោយអោយតែហ៊ានចូរមកជិតអញប្រយ័ត្នអញបាញ់!(អាខ្មៅកាន់កាំភ្លើងវេជុំវិញខ្លួន ភ្នែកវាក្រហមឆ្អៅបញ្ជាក់ថាវាមិនញញើតនិងបាញ់ជនណាដែលជាឧបសគ្គចំពោះមុខវា) ។

ពេលឃើញអ្នកឯទៀតរាថយដូច្នោះ អាខ្មៅបង្គំអោយនាយរាម និង អាស៊ើប្រញាប់ចាប់នាងសូណេតយកទៅដាក់ម៉ូតូ តែនាយម៉េងដែលរបួសជើងនៅមានស្មារតីរឹងប៉ឹងនៅឡើយ ហក់ទៅដាល់នាយខ្មៅ១ដៃចំថ្គាមបាក់ធ្មេញអស់មួយ ។ អាខ្មៅខឹងខ្លាំងណាស់ក៏តំរង់កាំភ្លើងបាញ់នាយម៉េងម្ដងទៀត តែត្រូវសាវ៉ាន់ឃើញទាន់ ក៏អោនក្បាលបុកសំដៅក្បាលពោះអាខ្មៅអោយដួលទាំងជំហរ មុននិងដួលវាភ្លាត់ដៃកេះកៃកាំភ្លើងលាន់ផ្ទូង ! គ្រាប់រត់ទៅបកស្បែកស្មាសាវ៉ាន់ខាងឆ្វេងមួយឆ្នូត ចេញឈាមហិតបទ្យាក់អាវជោគ ។

KHMER STORY LOVERS
សម្រាប់អ្នកចូលចិត្តអាន និង គាំទ្រសិល្បៈអក្សរសាស្ត្រខ្មែរ

មីងសុតមីងឡេងភ័យញ័រដូចកូនសត្វ ប្រឹងអោបនាងសូណេតជាប់រមួលចូលគ្នា១ដុំធំនៅក្នុងស្មៅ ទោះបីនាយតឿ នឹងនាយរាមប្រឹងទាយប្រទ្បេះយ៉ាងណាក៏មិនរបេះចេញពីគ្នាដែរ ។ សូរកាំភ្លើងធ្វើអោយអ្នកស្រុកប្រុសស្រីក្មេងចាស់ ដែលប្តើលមកមើលហេតុការណ៍ នាំគ្នាគេចរកកន្លែងពួនសិនមិនទាន់ហ៊ានចូលជិតភ្លាមទេ ។ តែគេកំពុងរកវិធីចូលជួយអ្នករងគ្រោះ ។

ឃើញសភាពការណ៍កាន់តែអាក្រក់ឡើង មិនអំណោយផលដល់ពួកវា . នាយរាមក៏ប្រមូលគ្នីគ្នារត់ឡើងម៉ូតូ បញ្ឆេះលាន់ងៀងៗចាកចេញពីទីនោះទៅ ។

ម៉ូដែលនិងម៉ូដែនបំរុងឡើងម៉ូតូទៅតាមពួកនាយរាមតែត្រូវនាយម៉េងឃាត់ថា៖

- ម៉ូដែល ! ម៉ូដែន ! ក្មួយកុំទៅតាមពួកវា ! ទៅផ្ទះវិញជាមួយពូ !

- ទេពូ ! ខ្ញុំត្រូវទៅតាមយកកាំភ្លើងពីអាខ្មៅវិញ ! ខ្ញុំមិនសុខចិត្តទេ វាបាញ់ពូ ! ខ្ញុំត្រូវប្រយៅវាម្តង !( ម៉ូដែលតប)

- មិនបាច់យកកាំភ្លើងពីវាទេ ! អោយវាយកទៅចុះ ឯងពីរនាក់ត្រូវទៅផ្ទះវិញជាមួយពូ ព្រោះម៉ាក់ឯងគាត់កំពុងរកឯង ! (ម៉េងស្រែកឃាត់ក្មួយ) ។

- ទេពូ ! ដាច់ខាតខ្ញុំត្រូវតែតាមយកកាំភ្លើងពីវាអោយបាន ( ម៉ូដែលពោលរួចហើយ នាំបងប្អូនហក់ឡើងម៉ូតូមួយម្នាក់ បើកបូចហោះដេញតាមក្រុមអាខ្មៅដែលទៅមុនបាត់ស្រមោលទៅហើយ)។

ពេលពួកអន្ធពាលចេញផុតអស់ទៅ អ្នកស្រុកនាំគ្នាមកចោមរោមមើលអ្នករបួស និងរកវិធីជួយសង្គ្រោះ ។

មីងឡេងមីងសុត និងនាងសូណេតភ័យណាស់ខំពិនិត្យមើលស្នាមរបួសអ្នកទាំងពីរ ។ នាងសូណេត និង មីងសុតអង្អែលមុខរបួសសារ៉ាន់ដោយក្តីអាណិតអាសូរ ។



ឯសារ៉ាន់បាននាងណេតអង្អែលសាច់ខ្លួនដូច្នោះ ក៏ធ្វើមុខជូរថ្ងូររំអួយថែមមើលទៅដូចជារបួសខ្លួនធ្ងន់ធ្ងរពេកណាស់ ។

បន្តិចមកនគរបាលពីរនាក់ស្ពាយកាំភ្លើងអាកា១ដើមជិះម៉ូតូសាន់យ៉ាន់ចាស់មួយឌុបគ្នាមកដល់កន្លែងកើតហេតុ ។ នគរបាលដែលស្ពាយកាំភ្លើងចុះពីម៉ូតូមកឈរយ៉ាងក្លាយានក្នុងចំណោមអ្នកស្រុក ដែលកំពុងចោមរោមមើលរបួសហើយសួរថា ៖

- បងប្អូនទាំងអស់គ្នាមានរឿងអីកើតឡើង ? អ្នកណាបង្ករអោយមានការផ្ទុះអាវុធអម្បាញ់មិញ ?

អ្នកស្រុកដណ្តើមគ្នាឆ្លើយរញ៉ីរញ៉ៃឡើងថា ៖

- ចោរប្លន់អម្បាញ់មិញនេះណាំ !(អ្នកស្រុកម្នាក់ឆ្លើយ)

- ទេ ! គឺពួកអាជិះម៉ូតូចាប់ស្រីៗ !(ពូម្នាក់ឆ្លើយកាត់)

- មិនមែនទេ ! វាប្រុងប្លន់មាសប្រាក់ដែលក្មួយសូណេតពាក់ ! ( អ្នកស្រុកម្នាក់ទៀតដណ្តើមឆ្លើយ)

- ទេ !អញមកដល់មុនគេអញឃើញច្បាស់និងភ្នែក(ពូម្នាក់ទៀតអះអាងឡើង) អាមួយនោះធាត់ខ្មៅស្កិលកាន់កាំភ្លើងបាញ់ប្អូនខាងនោះផ្ទូងៗ !!

- អត់ទេ !(តាម្នាក់ស្រែកបញ្ជាក់) បាញ់ឯណាដល់ទៅពីរផ្ទូង ដំបូងអញឮតែ១ផ្ទូងទេ ដល់យូរបន្តិចបានឮ ១ផ្ទូងទៀត !

- អើវាមិនដូចគ្នា ? មិនពីរផ្ទូងដដែលជាដដែល ? នគរបាលរាំងឃាត់អ្នកស្រុក

- បានហើយៗ !! បើដណ្តើមគ្នាឆ្លើយដូច្នេះខ្ញុំមិនដឹងស្តាប់ខាងណាយកខាងណីទេ ?មិនដឹងធ្វើរបាយការណ៍យ៉ាងម៉េចកើតទេ ! ។ ឥឡូវខ្ញុំសុំសួរទៅប្អូនអ្នករបួសនេះម្តងតើហេតុអ្វីបានជាមានការប្រយុទ្ធកើតឡើង ? អ្នកណាជាអ្នកកាន់អាវុធបាញ់ប្អូន

អោយរបួស ?

ម៉េងដែលមានរបួសជើង កំពុងត្រូវអ្នកស្រុកជួយរុំរបួសអោយ ឆ្លៀតឆ្លើយនិងសំនួរនគរបាលថា ៖

-ខ្ញុំពីនាក់សារ៉ាន់មកតាមរកក្មួយខ្ញុំ ចៃដន្យជួបពួកអាជិះម៉ូតូមួយក្រុមកំពុងចាប់នាងខាងណោះ ខ្ញុំពីរនាក់ក៏ចូលទៅជួយសង្គ្រោះនាង បណ្ដាលអោយគ្នាវាម្នាក់បាញ់ខ្ញុំនិងសារ៉ាន់ត្រូវរបួសដូចបងឃើញស្រាប់ ។

-ប្អូនឃើញពួកវាមានគ្នាប៉ុន្មាននាក់ ? មានកាំភ្លើងប៉ុន្មានដើម ? មានម៉ូតូប៉ុន្មានគ្រឿង ?(នគរបាលសួរបន្តនិងកត់ត្រាទុក) ។

-ពួកវាមានគ្នាប្រាំនាក់ មានម៉ូតូថ្មីៗទំនើបៗបួនគ្រឿង ឯកាំភ្លើងមានតែ១ដើមទេ ! ពួកវាទើបតែទៅអម្បាញ់មិញនេះ ទៅតាមផ្លូវនោះ ! (ម៉េងចង្អុលបង្ហាញផ្លូវនគរបាល)។

នគរបាលឮថាម៉ូតូពួកអាស្ទាវល្អៗទំនើបៗបំផុត ក៏បែរមកសម្លឹងមើលម៉ូតូខ្លួនដែលពុកសន្ទះនិងជាប់ភក់ស្រម៉ក ក៏នៅទ្រឹងបន្តិចទំនងជាគិតអ្វីមួយ ហើយបែរមើលផ្លូវដែលពួកអាស្ទាវចេញទៅ ងក់ក្បាលញញឹមតិចៗថា ៖"ពិតជាពួកអាស្ទាវទាំងនោះមែន ! ប៉ុន្តែទោះបីពួកវាមានស្លាបហោះ ក៏គេចមិនរួចពីដៃនគរបាលដែរ !"

អ្នកស្រុកផ្អើលមកកាន់តែច្រើនឡើង ខ្លះជួយលើកនាយម៉េង ខ្លះយកក្រមាមករុំរបួសអោយសារ៉ាន់ ។ តាម្នាក់គ្រហុបធ្មេញ ជាអ្នកស្រុកគៀនស្វាយដៃរខំនិយាយរអ៊ូតនៅមុខនគរបាលទាំងពីរនាក់ថា ៖

-ពួកអាក្មេងពាលអស់នេះព្រហើនណាស់ ! ខ្ញុំចង់ប្រដៅវា១ឈើច្រត់អោយស្គាល់ដៃចាស់ម្តង ! ស្តាយណាស់ខ្ញុំមកមិនទាន់កុំអីហ្នឹង !......ហ៊ឺអានាងអើយ !



អន្ទិតម្នាក់ឮតាពោលបែបហ្នឹកតបថា ៖

-បានហើយតាឡូញអើយ ! កុំសួរអួតពេកពួកវាមានកាំភ្លើងឯតា ឯងមានតែឈើច្រត់កញ្ជាស់មួយចង់លេងជាមួយវា តិចខកអត់បានហូបនំអន្សមភ្ជុំណាំតា !។

ក្រោយដែលសភាពការណ៍បានធូរស្រាលហើយ អ្នកស្រុកនាំគ្នាជួយគ្រាហ៍អ្នករបួសដាក់ឡាន ។ នាយម៉េងដែលរបួសជើងមិនធ្ងន់ធ្ង បានឡើងឡានទៅអង្គុយបើកដឹកសារ៉ាន់មីងសុតមីងឡេង និង នាងសូណេតចេញពីទីនោះសំដៅទៅមន្ទីរពេទ្យ ។ ពេទ្យក៏យកចិត្តទុកដាក់លាង និងរុំរបួសអោយអ្នកទាំងពីរជាថ្មីម្តងទៀតនិងចាក់ថ្នាំតេតាណូសអោយម្នាក់មួយម្ជុលផង ។

ទាំងអស់គ្នាចាកចេញពីមន្ទីរពេទ្យសំដៅមកផ្ទះនាងសូណេតនៅឯជ្រោយអំពិលវិញ ។

នេះជាលើកទីមួយហើយ ដែលមីងឡេងបានបង្ហាញការយកចិត្តទុកដាក់ចំពោះសារ៉ាន់ គាត់បានអួតប្រាប់ចិកឡោប្តីរបស់គាត់ ពីភាពក្លាហានរបស់សារ៉ាន់ដែលហ៊ានប្រយុទ្ធតទល់ជាមួយពួកពាលដែលមានកាំភ្លើងដើម្បីការពារសូណេតគួរអោយសរសើរពេកណាស់ ។

ក្រុមគ្រួសារចិកឡោបានខ្នះខ្នែងរៀបចាយទឹក ទទួលអ្នកក្លាហានទាំងពីរព្រោះម៉ោងមួយកន្លះហួសពេលថ្ងៃត្រង់ទៅហើយ ទាំងអស់គ្នាពុំទាន់ហូបបាយនៅឡើយ ។

គ្រាន់តែសូណេតលើកចានបាយមកដល់ ម៉េងដែលឃ្លានរមួលពោះយ៉ាងខ្លាំងក៏ចាប់ផ្តើមបរិភោគមុនគេឯង ឯនាយសារ៉ាន់បែជាអត់ឃ្លានបាយសោះ ព្រោះតែឆ្អែតនឹងចំណីមនោសញ្ចេតនាគេគិតតែពីញញឹមជាប់ហើយចេះតែសម្លឹងមើលទៅផ្ទះបាយ។

ពេលនោះអ្នកភូមិមកកុះករពេញផ្ទះ សួរសុខទុក្ខគ្រួសារចិកឡោ ។ ចិកឡោ


រក្សាសិទ្ធិគ្រប់យ៉ាង

ស្បែកខោខ្លីព្រៃខ្មៅរលើប លែងវង្វេងខ្លួនផ្ទែកខាងឈើទទេ បញ្ចេញក្បាលពោះសម្រុក អង្គុយគងរន្ទាក់ខ្លាបក់ផ្ទិតឈើក្តារឿមុខផ្ទះ ប្រាថ្នាផ្កាដៃផ្កាជើង អួតប្រាប់អ្នកស្រុកតាមសាច់រឿងហូហែរ ។ គាត់និយាយខ្មែរតែចេញខ្យល់ចិនធ្វើអោយអ្នកស្រុកខ្លះស្តាប់មិនមិនបានក៏នាំគ្នាទៅសួរបញ្ជាក់ពីមីងឡេងម្តងវិញ។មីងឡេងក៏បួបាច់ប្រាប់អ្នកស្រុកថា "កុំតែបានសាវ៉ាន់និងម៉េងមកជួយទាន់កុំអីពួកអា ម៉ូតូផ្តេផ្លានោះចាប់កូនស្រីគាត់ទៅបាត់ហើយ ! "ជាពិសេសគាត់ចង្អុលមកសាវ៉ាន់អួតថា "សាវ៉ាន់ក្លាហានណាស់ ហ៊ានវាយទប់និងពួកអាស្ពាវដែលមានកាំភ្លើង!"។ពួកកម្លោះៗក្នុងភូមិបួនប្រាំនាក់ដែលឈរស្តាប់នៅមុខផ្ទះ លីជួច្នោះក៏កើតក្តីច្រណែនក្នុងចិត្តយ៉ាងខ្លាំង ។មានយុវជនម្នាក់មានរាងស្គមកំព្រឹងជាមិត្តរបស់សាវ៉ាន់ដែរពោលឡើងថា ៖

-អាវ៉ាន់អើយ ! បើអញវិញមិនគ្រាន់តែប្រយុទ្ធជាមួយពួកពាលទេ អញថែមទាំងបីនាង ថ្មមៗយកទៅលាក់ទុកកន្លែងណាមួយអោយល្អ កុំអោយខ្លាំងតាមយាយីបាន !។

នាងក្រមុំម្នាក់ដែលឈរនៅក្បែរនោះលីដូច្នោះ ក៏ពោលហញ្ញាសអោយនាយសំគមវិញថា ៖

-ធ្វីយ ! ខ្ទើមណាស់ពូជាវអើយ !ហាឡើងសុទ្ធតែពួឈើកបីស្លូណោតរួច !រាងមើលតែជើងធ្វូបពរតែអាចក់ក្ដួយពួងងដែលអាយុ ១ខួបនោះមិនរួចផង !។

សំដីនាងក្រមុំធ្វើអោយអ្នកឯទៀត ដែលឈរក្បែនោះសើចតិលឡើង ឯនាយជាវក៏ខ្ទីរមុខសើចស្ញេញបញ្ចេញធ្មេញក្រហុបពីរគេចទៅពួនក្រោយខ្នងមិត្តភ័ក្តទៅ ។

ស្ងួណោតស្តាប់លីមិត្តភ័ក្តមកនិយាយលេងសើចពេញមុខផ្ទះនាងក៏អស់សំណើចសើចម្នាក់ឯង ។ ស្រស់ស្រីជាប់រវល់បំរើភ្ញៀវពុំបានចេញមកនិយាយលេងជាមួយមិត្ត



ភ័ក្តទេ ។ នាងឈរផ្អែកខ្នងនិងជញ្ជាំងបន្ទប់ឯភ្នែកកំពុងសាសងជាមួយសាវ៉ាន់ជាហេតុនាំអោយបាយក្នុងចានសាវ៉ាន់មិនរលួសសោះ ។ ម៉េងហូបអស់កន្លះចានងាកមកមើលបាយសាវ៉ាន់ឃើញនៅដដែលក៏សួរថា ៖



-អាខ្វាន់ ចឹបានមិនហូបបាយ ?

សាវ៉ាន់មិនឮម៉េងសួរទេ ព្រោះគេកំពុងតែញញឹមប៉ប្រិមធ្វើភ្នែកព្រិមៗសម្លឹងចំតួឯកស្រី នៃសាច់រឿងមនោសញ្ចេតនារបស់គេឯណោះ ។

ម៉េងយកដៃគ្រវាសពីមុខភ្នែកនាយសាវ៉ាន់តែនាយឥតមានព្រិចភ្នែកបន្តិចសោះ។ ចុះវាកំពុងបណ្តែតអារម្មណ៍ទៅណាហ្នឹង ? ម៉េងគិតហើយក៏យកស្លាបព្រាមកគ្រវាសពីមុខសាវ៉ាន់ ហើយគួសព្ឋប៊ិកៗទាល់តែសាវ៉ាន់ភ្ញាក់ ។

-ឯងមិនឃ្លានបាយទេឬអាខ្វាន់ ? ឯងរវល់គិតអីហ្នឹង ?

-ទេ ! អត់មានគិតអីទេ (សាវ៉ាន់តប)

-ទៅហូបបាយអោយលឿនឡើង ប្រញាប់ទៅឃ្លាំងវិញ (ម៉េងស្មើន )។

សាវ៉ាន់និងម៉េងហូបបាយរួច ក៏លាគ្រួសារចឹកឡោ និងមឹងសុតបំរុងឡើងឡានត្រលប់ទៅភ្នំពេញវិញ ។តែពេលនោះសាវ៉ាន់នៅឈរវេរាមិនព្រមឡើងឡានភ្នែកនាយរំពៃរកមើលនាងសូណេត ដែលគេចទៅណាបាត់ភ្លាមមួយរំពេច....
ហេតុអីបានជាចាត់មិនឃើញនាងចេញមកដើម្បីអោយគេបានលានាងផង ?សូម្បីពាក្យអរគុណ ១ម៉ាត់ ក៏គេពុំទាន់បានឮចេញពីមាត់នាងនៅឡើយ តើអំពើល្អ តើការតស៊ូប្រយុទ្ធដែលគេបានពុះពារសឹងស្លាប់សឹងរស់ ដើម្បីជួយនាងព្រឹកមិញនោះវាក្លាយទៅជាអត់ន័យទៅហើយឬ ?

សាវ៉ាន់យូរដៃរបួសឈានជើងឡើងឡានថ្នមៗ . នាយដូចជាល្វើយអស់កម្លាំងណាស់អង្គុយប្អែក បែបអស់សង្ឃឹមលើពូកឡានខាងស្តាំដៃម៉េង ។ រំពេចនោះសាវ៉ាន់ស្រាប់តែភ្ញាក់ព្រើត ព្រោះឃើញនាងសូណេតឈរសើចគ្រហាញមករកគេនៅក្បែរទ្វារឡានជិតបង្អើយ !ឱ !ថែនដីអ្នកពិតជាមូលមែន !មិនដឹងនាងឈរពួនចាំគេពីកាល



ណាមកទេអីចឹងបានជារកមើលនាងមិនឃើញ !។ រកហានិយាយអ្វីមិនកើត សាវ៉ាន់រំភើបពេក យកដៃបើកទ្វារឡានចង់ហក់ចុះទៅដីវិញ តែត្រូវម៉េងទាញអាវជាប់ ៖




-វាអាម៉េចទៀតហើយចុះឡើងៗអស់ទៅមុខរួចហើយឡានហ្នឹង(ម៉េងរអ៊ូ) សាវ៉ាន់អង្វរម៉េងអោយឈប់សិនហើយគេបំរុងនិងចុះដីវិញ តែត្រូវនាងសូណេតឃាត់ថា៖

-បងវ៉ាន់មិនបាច់ចុះមកទេ !ហ៎នេះខ្ញុំសូមជូនកញ្ចប់នំនេះដល់បងអរគុណបង ! អរគុណបងវ៉ាន់ណាស់ ! ( មាត់នាងពោលដៃនាងហុចកញ្ចប់ទៅសាវ៉ាន់ទាំងមុខញញឹមភ្នែកនាងសម្លឹងចំអ្នកក្លាហានដែលត្រូវរបួសដៃ...) សូមអោយបងឆាប់ជារបួសដៃ (ពីតាសូណេតពោលថ្នមសំដីព្ឋិតិចៗ តែសម្លេងនាងសែនត្រជាក់ស្រើបជ្រួតជ្រាបដល់ថ្លើមប្រមាត់កម្លោះសាវ៉ាន់ )។

-អរគុណណោតហើយ ដែលបានអោយនំខ្ញុំ១កញ្ចប់នេះ(សាវ៉ាន់ពោលទៅកាន់នាងសូណេត )

នាងកញ្ញាកាន់កញ្ចប់នំតូចមួយកញ្ចប់ទៀត ជូនទៅនាយម៉េងដែលកំពុងចំហរមាត់ភ្លុងមើលអ្នកទាំងពីរ...។

រថយន្តបើកសន្សឹមៗទៅមុខ .សាវ៉ាន់ខំងាកក្រោយមើលកញ្ញាសូណេត ។ម៉េងឃើញដូច្នោះពោលទៅកាន់សាវ៉ាន់ថា ៖

-សាវ៉ាន់ ! ឯងកុំភ្លេចថា ឯងនិងខ្ញុំមកតៀនស្វាយនេះគឺតាមមករកកាំភ្លើងមិនមែនមករកអីផ្សេងទេ ! ហើយខ្ញុំក៏មានការតាមរកក្មួយខ្ញុំដែរ ឥឡូវកាំភ្លើងរកមិនទាន់ឃើញឯក្មួយខ្ញុំក៏គេចខ្លួនទៅបាត់ទៀត ! វាទៅជាបាន ឯរបួសដៃរបួសជើងរៀងៗខ្លួនទៅវិញ ! ឥឡូវយើងគិតទៅច្រកណាទៀត ?

ម៉េងពោលតែម្នាក់ឯងនឹកស្មានថាសាវ៉ាន់កំពុងស្តាប់ តែសាវ៉ាន់ឥតបានយកចិត្តទុកដាក់ស្តាប់ទេ គេកំពុងលាកញ្ចប់នំ ដែលរុំនិងក្រម៉ាសូត្រពណ៌បៃតងសញ្ញាញដោយដៃបុប្ផាតៀនស្វាយ ចោលគន្ធពិដោរក្រអូបពេញឡាន ។ ម៉េងឃើញសាវ៉ាន់លានំអន្សមនំគមធំៗដាក់ឃើភ្លៅ ក៏ងាកមើលមកកញ្ចប់នំខ្លួនឃើញ តូចៗស្គមៗលាន់មាត់ថា ៖

-ឱ !ហេតុតែគេនៅកម្លោះគេទទួលអំណោយពីនាងក្រមុំសុទ្ធតែនំល្អៗធំៗឆ្ងាញ់ៗឯឯងកូន ១កន្ទេលទៅហើយគេអោយតិចតួច ព្រោះឯងវាចាស់ហួសដេទ្បេ ( ម៉េងពោលញាក់មុខដាក់សាវ៉ាន់ )។

-បងម៉េងនិយាយថាម៉េចហ្នឹង ? ច្រណែនឬ ?បើច្រណែនហ៎យកនំខ្ញុំទាំងអស់នេះទៅ !

សាវ៉ាន់ពោលហើយ ហុចកញ្ចប់នំបញ្ជោះអោយម៉េង . នាយម៉េងលូកដៃបំរុងកញ្ឆក់យកតែសាវ៉ាន់ដកនំមកវិញយ៉ាងលឿន ហើយខ្ចប់ទុកដាក់ឃើភ្លៅខ្លួនយ៉ាងស្រួល។



ម៉េងចាប់បន្តសំដីតទៅទៀតថា ៖

-នែ៎ សាវ៉ាន់យើងពីរនាក់មកតៀនស្វាយ មករកកាំភ្លើងមិនមែនមករកស្នេហាទេរ៉ុយ ! គឺឯងនេះហើយជាអ្នកនាំអាទិ៍ អោយកើតបញ្ហានេះឡើង !

សាវ៉ាន់ពោលតបទៅម៉េងវិញថា ៖

-មកដល់ម៉ោងនេះទៅហើយ យើងគួរឈប់និយាយពីរឿងកាំភ្លើងនេះទៅ ! ខ្ញុំសំរេចចិត្តថាឈប់គិតពីវាទៀតហើយ !

-ម៉េចសាវ៉ាន់ឯងនិយាយអីចឹង ? រឿងកាំភ្លើងនោះឯងអាចបំភ្លេចបានតែរឿងក្មួយខ្ញុំនោះឯងយល់យ៉ាងណា ? ឯងកុំភ្លេចថាកាំភ្លើងរបស់ឯងនោះឥឡូវនេះវានៅក្នុងដៃក្មួយខ្ញុំ ឬក៏នៅក្នុងដៃក្រុមរបស់វាហើយចង់មិនចង់ គឺយើងជាអ្នកបង្ករលក្ខណៈអោយកាំភ្លើងនោះបានធ្លាក់ក្នុងដៃក្មេងៗទាំងនោះ ។

រំពេចនោះស្រាប់តែ ទូរស័ព្ទដៃដែលម៉េងដាក់ក្បែរខ្លួននោះបន្លឺសម្លេងតេតៗឡើង ។ ម៉េងលើកទូរស័ព្ទមកស្តាប់គឺសម្លេងពូឈុំ ៖

-ម៉េង ! ឯងកំពុងនៅទីណាឥឡូវនេះ ? (សម្លេងពូឈុំក្នុងទូរស័ព្ទ) ខ្ញុំចាំឯង១ព្រឹកទៅហើយ មិនឃើញឯងយកឡានមកដឹកទំនិញ ១ជើងទៀតសោះ ឯងរវល់ទៅណាហ្នឹង ?

-បាទលោកមា (ម៉េងឆ្លើយតប) ខ្ញុំមានធុរៈផ្ទាល់ខ្លួន

-ម៉េងឯងមានបានឃើញសាវ៉ាន់ទេ?តាំងពីព្រឹកដែលឯងចេញឡានមកក៏បាត់ពីឃ្លាំងដែរឯងមានបានជួបវាទេ ?

-បាទលោកមា ខ្ញុំបានដើរជាមួយសាវ៉ាន់តាំងពីព្រឹក ឥឡូវវាកំពុងជិះឡានជាមួយខ្ញុំត្រលប់ទៅឃ្លាំងវិញហើយលោកមា ។

-អើ ! បើអីចឹងល្អហើយ ! ឯងត្រូវនាំវាមកជួបខ្ញុំជាប្រញាប់ខ្ញុំមានការសំខាន់

ចង់និយាយជាមួយវា !

ចប់ការសន្ទនា ម៉ែងដាក់ទូរស័ព្ទចុះហើយងាកទៅមើលមុខសារ៉ាន់ ឯសារ៉ាន់មើលមុខម៉ែងវិញដែរ ។ សារ៉ាន់ពោលឡើងថា ៖

-ខ្ញុំដឹងហើយ ! មាឈុំចង់ជួបខ្ញុំគ្មានរឿងអីក្រៅពីរឿងកាំភ្លើងនោះទេ !ច្បាស់ជាបងម៉ាចគាត់ទៅរាយការណ៍ប្រាប់មាឈុំហើយ !

ព្រោះព្រឹកមិញខ្ញុំបានប្រហែសធ្វើអោយធ្លាក់កាំភ្លើងមុខគាត់ ប៉ុន្តែខ្ញុំមិនទៅខ្វល់អីទេ ! ខ្ញុំនិងទៅបកស្រាយជំរាបមាឈុំតាមដំណើររឿង ។

ពិតដូចសារ៉ាន់ស្មានមិនខុសមែន ,កាលពីព្រឹកពេលដែលសារ៉ាន់ចេញពីឃ្លាំងទៅតាមទ្បាននាយម៉ែង ដើម្បីយកកាំភ្លើងមកវិញនោះនាងម៉ាចបានទៅរាយការណ៍ប្រាប់ពូឈុំថា ៖

-លោកមា ! វិវរហើយ ! ខ្ញុំបានឃើញអាខ្វាន់វាមានកាំភ្លើងខ្លី១ដើម សៀតនៅចង្កេះខោវា !

-កុំមកកុហក់អញខ្វាច ! អាសារ៉ាន់ណាមានកាំភ្លើង ! ក្រែងវាកាន់កាំភ្លើងជ័រក្មេងលេងទេដឹង ! ចេះតែចោទវាផ្ដេសផ្ដាស ។

-ពិតមែនណាំលោកមា ! កាំភ្លើងជ័រអីធ្លាក់ឮស្នូរគ្គុករាងធ្ងន់ដូចដុំដែក ! ហើយខ្ញុំឃើញវាធ្វើភ្នែកក្រឡីហុក្រឡាប់ អោនរើសដាក់ក្នុងអាវវាវិញយ៉ាងរហ័ស

-ចុះបើឯងឃើញពេលនោះម៉េចមិនប្រាប់អញភ្លាមអញនិងហៅវាសួររឿងហ្នឹង ?

-ខ្ញុំម៉េចហ៊ានប្រាប់លោកមាភ្លាម ខ្ញុំខ្លាចវាបាញ់ខ្ញុំព្រោះវាទើបឈ្លោះជាមួយខ្ញុំម្សិលមិញផង !

-អញស្គាល់អាសារ៉ាន់តាំងពីវានៅតូចម្ល៉េះ វាមិនមានចិត្តខ្មៅដល់ថ្នាក់គ្រាន់តែទាស់សំដីបន្តិចបន្តួចជាមួយឯង ហើយហ៊ានលើកកាំភ្លើងបាញ់ឯងនោះទេ !



-ហ៊ឺ ! លោកមាអើយ ក្មេងៗសម័យឥឡូវទុកចិត្តមិនបានទេ ! ខ្លះចេះខូចតាំងពីញាស់ ខ្លះចេះភូតចេះកុហក់ម៉ែឪបងប្អូន ខ្លះកោង កាចចេះបាញ់ ចេះកាប់ចាក់ ចេះលួចចេះប្លន់ណាំលោកមា

-វាមិនមែនខូចតែទាំងអស់នោះទេ ! វាមានក្មេងល្អ ក្មេងកូនអ្នកមានពូជអម្បូរគេចេះស្ដាប់បង្គាប់ម៉ែឪ គ្រូអាចារ្យ គេខំរៀនសូត្រ ក្មេងល្អមានច្រើនណាស់ក្មេងខិល



ខូចមានតែ១ចំនួនតូចទេ ឯងកុំនិយាយម៉ៅសរុបទាំងអស់ដូច្នេះ វាខូចកូនគេអ្នកផ្ទៃថ្មី អស់ហើយ ។ ណ្ហើយបានហើយខ្លាច ! កុំប្ដូចាច់ច្រើនពេកទៅ ! ទៅផ្ទះបាយទៅ ! ពូឈុំដេញនាងម៉ាច អោយត្រឡប់ទៅផ្ទះបាយវិញ តែក្នុងខួរក្បាលគាត់នៅតែគិតពិចារណាពាក្យនាងម៉ាចដែលថាបានឃើញសារ៉ាន់មានកាំភ្លើងខ្លី.....។

ពេលរសៀល ក្រោយពីបានទូរសំព្ទជួបនាយម៉េងរួចហើយ ពូឈុំអង្គុយបង្អួយបារីចាំមើលផ្លូវម៉េងនិងសារ៉ាន់ ។

កន្លះម៉ោងក្រោយមក រថយន្តម៉េងបរចូលមកឈប់ស្ងៀមកណ្ដាលទីធ្លា ។ អ្នករបួសទាំងពីរនាក់ចុះពីឡាន....

ម៉េងរុំជើងដោយក្រណាត់រុំរបួស ហើយស្ទៀកខោពីឈើទៀងចំស្ដើងដើរចាក់ខ្ញើចៗ ឯសារ៉ាន់រុំដៃយួរស្ពាកដើរទុយមុយចូលមករកពូឈុំ ។ ពូឈុំភ្ញាក់ដោយឃើញអ្នកទាំងពីរមានរបួស ក៏សួរថា ៖

-ឯងពីរនាក់ហ្នឹងទើបមកពីសមរភូមិណា ?

-បាទ !សមរភូមិត្បៀនស្វាយបាទ !(ម៉េងតប)

-ត្បៀនស្វាយ ! កុំលេងសើចច្រើនពេកប្រាប់គ្នាអោយដឹងផង ! ហេតុអីបានជាពួកឯងមានរបួស ? (ពូឈុំសួរបញ្ជាក់ម៉េង) ។

-រឿងនេះទុកអោយសារ៉ាន់វាបកស្រាយប្រាប់លោកមាទៅចុះ ! ព្រោះមកពីវាហ្នឹងមេនាំរឿង(ម៉េងអង្គុយចុះក្បែរពូឈុំ ហើយពោលទាំងមុខជូរ ព្រោះរបួសជើងគេចាប់ផ្ដើមឈឺ)។ ពូឈុំងាកមកមើលមុខសារ៉ាន់ហើយសួរថា ៖

-ឯងនៅធ្វើការជាមួយអញសុខៗព្រឹកមិញ ស្រាប់តែគេចទៅណាបាត់ហើយបែរជាមានរបួសនៅត្បៀនស្វាយទៅវិញ ?ឯងនេះដូចជាប្លែកណាស់ មានគេប្រាប់អញថាឯងមានកាំភ្លើងជាប់ខ្លួនផងមែនទេ ? ។

-បាទលោកមា !ពិតជាមានមែន !រឿងកាំភ្លើងចង្រៃនោះហើយដែលនាំអោយខ្ញុំនិងបងម៉េងមានរបួសនៅត្បៀនស្វាយនោះ ។

-ឯងមានកាំភ្លើងមែនឬ ? ឯងបានពីណាមក ? ឥឡូវនៅឯណាកាំភ្លើងនោះយកមកអោយអញមើល !

សារ៉ាន់និយាយរៀបរាប់រឿងរ៉ាវហូហែប្រាប់ពូឈុំ តាំងពីពេលគេបានរើសកាំភ្លើងនោះនៅក្រោយឃ្លាំង រហូតដល់មានការប្រយុទ្ធនៅត្បៀនស្វាយជួយសង្គ្រោះនាងស្វណោតក្លយពូឈុំដែលត្រូវពួកយុវជនពាលបំរុងចាប់ពង្រត់ដាក់ម៉ូតូយកទៅ ។

ពេលដែលសារ៉ាន់កំពុងនិយាយរំលឹករឿងកាំភ្លើងនោះ ជួនជាពូជិមអ្នកចាក់ស៊ីក្លូដែលជាជនទីមួយ រើសបានកាំភ្លើងនោះបានមុនគេដើរចូលមក កាន់កញ្ចប់បារីកន្លះស៊ុងបំរុងយកមកអោយពូឈុំជាសគុណ ដែលពូឈុំបានធ្វើអំណោយសំបកឡាំងដល់គាត់កាលពីព្រឹក ។ ពូជិមមិនបានដឹងថាសារ៉ាន់លួចចូលទៅយកកាំភ្លើងនៅក្នុងផ្ទះគាត់ទេ ។ ប៉ុន្តែពេលដែលគាត់អង្គុយស្ដាប់សាច់រឿងរបស់សារ៉ាន់មួយចប់ទៅ ទើបគាត់ដឹងថាកាំភ្លើងដែលគាត់លាក់ក្នុងភួយនោះ ត្រូវសារ៉ាន់ចូលទៅយកពីក្នុងផ្ទះគាត់បាត់ទៅហើយ ។ ពូជិមធ្វើភ្នែកម៉ិកៗចង់ហាមាត់និយាយអ្វីមួយ តែវាដូចជាគាំងនិយាយមិនចេញ ។ព្រោះតាមពិតរឿងកាំភ្លើងនោះ គឺរូបគាត់ជាអ្នកដើមភ្លើង ពុំមែនសារ៉ាន់ទេ ។ សារ៉ាន់បានបន្តសំដីទៀតថា ៖

-ឥឡូវកាំភ្លើងនោះបានធ្លាក់ដល់ដៃក្លយរបស់បងម៉េង និងក្រុមរបស់គេហើយ ! ជាអ្នកនាំអោយកើតរឿងរ៉ាវអាក្រក់នេះឡើងដោយអចេតនា!ខ្ញុំពិតជាមានកំហុសក្នុងរឿងនេះ !។

-ទេ ! សាវ៉ាន់ឯងជាអ្នករើសកាំភ្លើងមែន តែឯងមិនមែនជាអ្នកបង្ករលក្ខណៈអោយកាំភ្លើងនេះធ្លាក់ដល់ដៃក្មួយខ្ញុំទេ ! គឺរូបខ្ញុំឯណោះទេជាអ្នកខុស ! គឺខ្ញុំនេះហើយបានយកកាំភ្លើងនោះទៅផ្ញើបងស្រីខ្ញុំ បណ្តាលអោយក្មួយខ្ញុំលួចយកទៅ ! ។ (ម៉េងពោលអះអាងទទួលកំហុសបន្តពីសាវ៉ាន់) ។

-ទេ ! អ្នកទាំងពីរជាអ្នករងគ្រោះដោយសាខ្ញុំឯនេះទេ ! (សម្លេងពូជិមឆ្លើយកាត់គេឯងឡើងដោយគ្មានអ្នកសួរ ទាំងអស់គ្នាភ្ញាក់ងាកមើលទៅគាត់ដោយក្តីងឿងឆ្ងល់) គឺខ្ញុំនេះហើយជាអ្នករើសកាំភ្លើងនោះមុនគេបំផុត! (ទាំងអស់គ្នាក៏ងាកមកប្រុងហមាត់ស្តាប់រឿងពូជិមម្តងវិញ ។ ពូបានរៀបរាប់ហូរហែតាំងពីប្រពន្ធគាត់ប្រទះឃើញកាំភ្លើងលើស៊ីក្លូ រហូតដល់កាំភ្លើងនោះធ្លាក់ដល់ដៃសាវ៉ាន់...) ។

ពេលដឹងប្រភពដើមកាំភ្លើងនោះហើយ សាវ៉ាន់ក៏ងាកមើលទៅនាងម៉ាចដែលអង្គុយស្តាប់នៅក្បែរនោះដែល ។ដោយនាយមានចរិកជាអ្នកលេងសើចច្រើនផង ក៏ធ្វើជាសំឡេក់សម្លឹងរករឿងនាងម៉ាច ដែលបានទទួលពិតតាឈុំ ។ នាងម៉ាចមានខ្លួនក៏ទទ្ធក្រម៉ាជើរគេចទៅផ្ទះបាយបាត់ទៅ ។ សាវ៉ាន់ឃើញដូច្នោះលួចសើចម្នាក់ឯង គិតក្នុងចិត្តថា "ថ្ងៃណាមួយធ្វើបាបបងម៉ាចអោយដឹងដៃម្តង !" ។

ពូឈុំងាកមើលម៉េងចង់ដឹងម៉េងគិតយ៉ាងណា ដើម្បីតាមរកក្មួយរបស់គេនិងកាំភ្លើងមកវិញ ។ គាត់ជាចាស់ទុំតែងមានក្តីបារម្ភរឿងគ្រោះថ្នាក់ចំពោះក្មេងៗ ដែលកាន់កាំភ្លើង ហើយកំពុងស្ថិតនៅក្នុងហ្វូងពួកពាល ។

ម៉េងខ្វល់ក្នុងចិត្តខ្លាំង ទាញទូរស័ព្ទបំរុងនិយាយទៅអ្នកស្រីអោគា តែមកគិតថាបងស្រីរបស់ខ្លួនមានសុខភាពមិនល្អ មិនទាន់ចង់អោយដឹងរឿងនេះភ្លាមៗទេ ។ម៉េងដាក់ទូរស័ព្ទចុះ ហើយសំរេចចិត្តថាត្រូវទៅតាមរកក្មួយម្តងទៀត ។គេពុំបានគិតពីរឿងដើងដែលកំពុងឈឺចាប់ក្នុងសមដែរនោះទេ ។



-ម៉េង!ឯងត្រូវប្រញាប់តាមរកក្មួយឯងភ្លាមទៅ! (ពូឈុំនិយាយទៅកាន់ម៉េង) រឿងនេះបណ្តែតបណ្តោយយូរមិនបានទេ ក្មួយរបស់ឯងទាំងពីរនៅក្នុងហ្វូងក្មេងខិលខូចមានទាំងមាសប្រាក់ជាប់និងខ្លួនផង ស្រួលមិនស្រួលវាអាចមានគ្រោះថ្នាក់ដល់ជីវិតក៏ថាបាន ។ ឯងមើលកាសែតគេចុះផ្សាយរាល់ថ្ងៃ រឿងប្លន់រឿងឃាតកម្ម លួចកេងប្រវ័ញ្ចគ្រប់បែបយ៉ាង ។ ការចុះផ្សាយទាំងនោះ ជាមេរៀនអោយយើងគ្រប់គ្នាជាប្រជាជនចេះគិតពិចារណាអោយបានយល់ អោយស្គាល់កលល្បិចគ្រប់បែបយ៉ាង ។ របស់ជនខិលខូច ។ យើងត្រូវមានស្មារតីប្រុងប្រយ័ត្ន កុំធ្វេសប្រហែសអោយសោះជាមួយជនពាល ។ ទៅ ! ទៅប្រញាប់ទៅរកក្មួយឯងទៅ ។ អោយសាវ៉ាន់វាទៅជាមួយឯងផងគ្រាន់បានជាគ្នា ។

ពេលនោះពូជិមក៏បានធានាខ្លួនទៅជាមួយម៉េងនិងសាវ៉ាន់ដែរ ។អ្នកទាំងបីរៀបឡើងរថយន្តចេញដំណើរដើម្បីបំពេញបេសកកម្មពិសេស ក៏ស្រាប់តែ......មានសម្លេងទូរស័ព្ទបន្លឺតេតៗក្នុងដៃនាយម៉េង ។ ម៉េងលើកទូរស័ព្ទស្តាប់ គឺសម្លេងរបស់ម៉ូដែល ៖

"ពូម៉េង ! របួសជើងពូមិនអីទេឬ ? ខ្ញុំពីរនាក់អារ៉ូនកំពុងស្ថិតនៅជាយក្រុងខ្ញុំកំពុងតាមរកអាខ្មៅ ! ខ្ញុំនិងយកកាំភ្លើងពីវាវិញ ! ហើយប្រដៅវាអោយដឹងដៃម្តងវាផ្ញើមធំហ៊ានបាញ់ពូ ! សូមពូជួយជំរាបម៉ាក់ខ្ញុំផងថាយប់នេះខ្ញុំមិនបានត្រលប់ទៅផ្ទះវិញទេកុំអោយម៉ាក់បារម្ភពីខ្ញុំនិងអារ៉ូនអី ខ្ញុំពីនាក់សុខសប្បាយជាទេ ! មានបញ្ហាអីខ្ញុំនិងជំរាបពូមិនខាន ។ ខ្ញុំសូមលាសិនហើយពូ ! បាយៗ !! ។

សម្លេងម៉ូដែលបានបញ្ចប់ត្រឹម នេះ ម៉េងខំប្រឹងស្រែកសួរតាមទូរស័ព្ទទៅក្មួយវិញថា ៖

"ម៉ូដែល ! ក្មួយទៅជាយក្រុងម្តុំណា ? ពូកំពុងតាមរកឯងណាំ !

ពុំព្រួសម្លេងឆ្លើយតបវិញឡើយ ទូរស័ព្ទបានកាត់ផ្តាច់ទៅហើយ ។ ម៉េងដាក់ទូរស័ព្ទចុះ ទឹកមុខស្លែនកង្វល់ ។ ទាំងអស់គ្នាសម្លឹងមើលម៉េង . មួយសន្ទុះម៉េងពោលឡើងថា ៖

_វីវរហើយ !ម៉ូដែលនិងម៉ូដែនតាមទៅយកកាំភ្លើងពីអាខ្មៅវិញមិនមែនជាការងាយទេ !អាខ្មៅវាប្រាកដជាមិនអោយកាំភ្លើងមកក្មួយខ្ញុំវិញទេវាអាចមានការប្រយុទ្ធដណ្តើមកាំភ្លើងគ្នារវាងអាខ្មៅនិងក្មួយខ្ញុំទាំងពីរនាក់ ។ អាខ្មៅជាមនុស្សពាល បើវាថាបាញ់គឺបាញ់ហើយ !។ ពេលនេះយើងមិនដឹងថាគេនៅជាយក្រុងកន្លែងណាទេ ធ្វើម៉េចយើងជួយពួកគេបាន ? ។

សារ៉ាន់ពោលឡើងថា ៖

_បើតាមខ្ញុំយល់ ជាយក្រុងគ្មានកន្លែងណាក្រៅពីត្បៀនស្វាយទេ ! យើងគួរត្រលប់ទៅរកពួកគេឯត្បៀនស្វាយវិញទៅឬ ?

ពេលនោះនាងម៉ាចដើរត្រឡប់ពីផ្ទះបាយ យួរកំសៀវទឹកក្តៅមកឆុងតែអោយពូឈុំ ឮសារ៉ាន់ពោលថាត្រឡប់ទៅត្បៀនស្វាយវិញក៏ពោលថា ៖

_វិលទៅវិញទៅមក មួយល្ងាចទៅហើយលឺតែត្បៀនស្វាយៗ អីក៏ជាប់ចិត្តនឹងត្បៀនស្វាយហ្នឹងម្ល៉េះ ?...តាមយោបល់ខ្ញុំមិនមិនចាំបាច់ដើររកច្រើនទេ ទៅប្តឹងនគរបាលអោយជួយរកតែម្តងទៅវាល្អជាង !"នាងម៉ាចពោលហើយលួចចោលកន្ទុយភ្នែកមើលសារ៉ាន់" ឯសារ៉ាន់លឺនាងម៉ាចថាប្តឹងនគរបាលក៏ប្រញាប់ឆ្លើយឡើងថា ៖

_ទេ ! ប្តឹងនគរបាលមិនទាន់បានទេ ! នគរបាលដឹងរឿងកាំភ្លើងនាំវែងឆ្ងាយទៀតហើយ !។

នាងម៉ាចធ្វើមិនលឺសារ៉ាន់និយាយហើយក៏និយាយជាមួយម៉េងបន្តទៀតថា ៖

_ហ៊ាម៉េង !ទៅប្តឹងនគរបាលទៅ!ចាំខ្ញុំនាំទៅជួបនគរបាលសង្កាត់ពីនាក់ដែល



ខ្ញុំស្គាល់អោយគាត់ធ្វើកំណត់ហេតុអ្នកណាដឹសបានកាំភ្លើង អ្នកណាលាក់កាំភ្លើងទុកលក់ អ្នកណាត្រូវមានទោស អ្នកណាអីអោយវាច្បាស់លាស់ឡើង ! ទើបគេតាមរកកាំភ្លើងនិងក្មួយហ៊ាម៉េងឯងឃើញ !។

សារ៉ាន់មុខក្រហមខឹងណាស់ហាមាត់បំរុងតតាំងជាមួយនាងម៉ាច តែត្រូវពូឈុំលើកដៃរាឃាត់ហើយអាកាត់ឡើងថា ៖

_ខ្មាច ! តុំចេះមាត់ ទៅផ្ទះបាយវិញទៅ ! (នាងម៉ាចយួរកាំសៀវទឹកដើរតយម៉ែយទៅផ្ទះបាយវិញ) ។

ពូឈុំងាកមកនិយាយជាមួយម៉េង

_ឥឡូវបើពួកឯងនៅជជែកគ្នាទីនេះតទៅទៀតក៏ឥតប្រយោជន៍ដែរ យកល្អគួរនាំគ្នាឆាប់ចេញដំណើររកពួកគេទៅ ! ។ ចំណែកខ្ញុំត្រូវទៅរាយការណ៍ប្រាប់នគរបាលអោយដឹងរឿងនេះផងដែរ ហើយយើងស្នើសុំជំនួយពីនគរបាលអោយជួយស្វែងរកក្មេងទាំងពីរផង នគរបាល់គេពិតជាមានមធ្យោបាយច្រើនជាងយើង !។

ដោយស្តាប់តាមយោបល់ពូឈុំ អ្នកទាំងបីក៏ឡើងរថយន្តចេញដំណើរយ៉ាងប្រញាប់ប្រញាល់ តែគោលដៅរបស់គេពុំទាន់ដឹងថា ត្រូវទៅរកយុវជនទាំងពីរនៅទីណាច្បាស់លាស់ឡើយ ។




ភ្លៀងរលឹមស្រិចៗ ទ្រនិចនាឡិកាមិនទាន់ចង្អុលម៉ោង១៨ត្រឹមត្រូវផងតែមេឃងងឹតស៊ុបឈានចូលរាត្រីកាលទៅហើយ ។

នៅតាមវិថីនានាក្នុងទីក្រុងភ្នំពេញ ចរាចរនៃយានជំនិះគ្រប់ប្រភេទ ពុំបានបន្ថយសកម្មភាពទេ ។ ភ្លើងចង្កៀងឡានម៉ូតូ បាចសាចពន្លឺក្រហមសខ្ចាត់ខ្ចែងបញ្ជាក់អោយឃើញនូវការរីកចំរើនយ៉ាងឆាប់រហ័សនៃរាជធានីភ្នំពេញ ផ្នែកចរាចរ និងដឹកជញ្ជូន ។

ម៉េងបើកឡានផ្ទួលមួយជុំក្រុងភ្នំពេញហើយ ពុំទាន់មានពន្លឺអ្វីបន្តិចដល់ការស្វែងរករបស់គេនៅឡើយ ។

ពូជិមដែលអង្គុយទន្ទឹមនិងម៉េងបន្លឺវាចាថា ៖

-យប់ងងឹតទៅហើយ យើងបើកឡានដើររកតាមជាយក្រុងដូច្នេះ មិនងាយ



ឃើញទេ ព្រោះផ្ទះក៏ច្រើនស្លេកស្លះក្រឡុកក្រឡៀតក៏សម្បូរណ៍ ហើយអាចនិងមានគ្រោះថ្នាក់ដល់យើងទាំងបីនាក់ផង ។សព្វថ្ងៃមានមនុស្សពាលសាហាវៗណាស់វាច្រើនលាក់ខ្លួននៅជាយក្រុងចេញប្លន់អ្នកដំណើរ ។

សារ៉ាន់បន្តសំដីពីពូជិមថា ៖

-រឿងជួបចោរប្លន់ឬមនុស្សពាលវាជារឿងចៃដន្យម្តងម្កាលទេ តែរឿងសំខាន់ចំពោះមុខគឺរឿងខ្ញុំឃ្លានបាយ ។យើងគួរឈប់ឡានទទួលទានបាយកន្លែងណាមួយសិនទៅឬ ? ព្រោះក្រពះខ្ញុំវាទាមទារខ្លាំងណាស់ !។

ម៉េងលឺដូច្នោះ ក៏ដាក់មួយផ្តៃអោយសារ៉ាន់ថា ៖

-ឥឡូវនេះ អ្នកប្រុសឃ្លានបាយហើយឬ? ចុះព្រឹកមិញនៅគៀនស្វាយនាងកញ្ញាស្មូណេតដាក់បាយអោយអ្នកប្រុសទាំងគោមអោយហូប ម៉េចអ្នកប្រុសធ្វើច្រមច្រំដូចអត់ឃ្លាន ?

សារ៉ាន់លឺម៉េងដាក់អោយដូច្នោះក៏សើចញឹមៗព្រោះម៉េងថាចំចំណុចពេកក៏តបវិញថា ៖

-ព្រឹកមិញវាផ្សេង ឥឡូវវាផ្សេង !សាច់រឿងវាខុសគ្នា !

ពូជិមមិនដឹងសាច់រឿងសារ៉ាន់នៅគៀនស្វាយអីទេ គាត់លឺសារ៉ាន់ថាឃ្លានបាយគាត់ក៏នឹកទៅដល់កូនកែវ ដែលគាត់ធ្លាប់ក្រាលក្រពះពេលល្ងាចដែរ ។ បើមិនបានដាក់១កូនកែវទេ គាត់ដេកមិនលក់គិតអ្វីមិនចេញឡើយ ។គាត់បែរទៅនិយាយជាមួយសារ៉ាន់ថា ៖

ម៉េងអើយ ! បើសារ៉ាន់វាឃ្លានបាយហើយ គួរឈប់ទៅរកកន្លែងទទួលទានសិនទៅហ្អែ ? ឆ្អាងណោះក៏ក្រពះវាទាមទាដែរណាំ !

ដោយមតិភាគច្រើននៅលើឡានទាមទាហូបបាយ ម៉េងក៏បញ្ឈប់រថយន្តនៅ

មុខភោជនដ្ឋានមួយជិតផ្លូវចូលទៅទួលគោក ។

ពូជិមពុំបានចូលរួមគុយជាមួយអ្នកទាំងពីរទេ គាត់ដើរហួសទៅអង្គុយនៅកូនរានលក់សាច់ក្រៀម ដែលមានកែវធំៗពីរដាក់ស្រាត្រាំអាញ្ញី បណ្ដូលពេជ្រ ឈាមពស់វែក ។ល។ហើយគាត់ងាកមកលើកដៃជាសញ្ញាអោយអ្នកទាំងពីរហូបបាយចុះកុំចាំគាត់អី ។ពូជិមបង្គាប់អ្នកលក់ជួសស្រាថ្នាំប៉ូវ១កែវអោយគាត់និងសាច់បបែលជុតយ៉ាងឈ្ងុយមួយជុំមក ។ គាត់អង្គុយផឹកក្លែមសាច់បបែលយ៉ាងឆ្ងាញ់ ។ នៅក្បែរគាត់គឺ ពូស៊ីក្ដុបួន



ប្រាំនាក់ទៀត ដែលក្លាយជាសមាជិកផឹកស៊ីជាមួយពូជិមមួយរំពេចមិនបាច់ស្គាល់គ្នាពីកាលណាមកទេ ។ ពួកគាត់ជជែកព្រោកប្រាជ្ញស្រវឹងងីល ។ ពេលផឹកស៊ីដូច្នេះគេក្លាយជាមិត្តស្និទ្ធស្នាល កាន់កែវកាន់ពែងជល់គ្នានិយាយទះស្មាទះដៃគ្នា វុញគ្នាទៅវិញទៅ



មកសើចក្អាកក្អាយដូចជាពួកគាត់កំពុងស្ថិតនៅកណ្ដាលពិភពដ៏សែនរីករាយណាមួយ។ ឥទ្ធិពលនៃជាតិស្រវឹងស្រាថ្នាំត្រាំអាញ្ញី អាចអោយពួកបំភ្លេចបាន មួយគ្រាន្ធូវទុក្ខលំបាកប្រចាំថ្ងៃក្នុងជីវភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ។ ពួកគាត់គិតថាជីវិតសប្បាយរីករាយបំផុតគឺអស់ត្រឹមកែវស្រានេះហើយ ។

នៅក្នុងភោជនីយដ្ឋានឯណោះ ម៉េងនិងសាវ៉ាន់កំពុងហូបស្រាប់តែមានសម្លេងទូរស័ព្ទបន្លឺតេតៗក្នុងហោប៉ៅខោម៉េង ម៉េងលើកទូរស័ព្ទមកស្ដាប់ . សម្លេងស្ត្រីម្នាក់ម៉េងស្គាល់ច្បាស់ជាសម្លេងបងស្រីខ្លួន :

- ម៉េងហា !ម៉េងឯងបានជួបក្មួយឯងពីរនាក់ហើយឬនៅ ?បងចាំស្ដាប់ដំណឹងឯងតាំងពីព្រឹក ម៉េចស្ងាត់ឈឹងមិនអោយដំណឹងបងសោះ ?

- បាទបងមីខ្ញុំបានជួបម៉ូដែលនិងម៉ូដែនកាលពីថ្ងៃត្រង់ព្រឹកមិញនៅគៀនស្វាយ។ តែគេបានគេចខ្លួនទៅបាត់ក្រោយដែលមានការប្រយុទ្ធគ្នាមួយ ! ។

- ពួកកូនពីរនាក់ប្រយុទ្ធជាមួយអ្នកណា ?មានរបួសទេ ?មានប្រើកាំភ្លើងទេ ? ម៉េចបានម៉េងឯងមិនប្រាប់បងអោយដឹងផង ?។

- បាទពួកគេអត់មានរបួសទេ ។ ក្មួយទាំងពីរនាក់ បានដើរជាមួយពួកក្មេងខិលខូច ។ពួកខិលខូចទាំងនោះវាជិះម៉ូតូចាប់កូនស្រីគេម្នាក់នៅគៀនស្វាយ ។ ខ្ញុំនិងសាវ៉ាន់ទៅទាន់ជួយនាងនោះ បណ្ដាលអោយមានការប្រយុទ្ធគ្នា ។ ពេលនោះមានអាស្ការម្នាក់ឈ្មោះអាខ្មៅបានកញ្ឆក់យកកាំភ្លើងពីចង្កេះម៉ូដែលបាញ់មកលើខ្ញុំនិងសាវ៉ាន់គ្រាន់តែមានរបួសបន្តិចបន្តួច ។ សូមកុំបារម្ភអីខ្ញុំកំពុងបើកឡានតាមរកក្មួយៗហើយ ។

- ហ៊ឺយ ! ព្រះជាម្ចាស់អើយ ! (អ្នកស្រីដកដង្ហើមធំនិងលាន់មាត់ដោយភ្ញាក់ងឿងរាត់បន្តសំដីក្នុងទូរស័ព្ទទៀតថា) ៖

- ចំពេលជាវាគាត់មិនទៅផង បងមិនដឹងគិតយ៉ាងណាទេបងពិបាកចិត្តណាស់។

ព្រឹកមិញបងបានប្រាប់ទៅក្រុមហ៊ុនអោយគេចាត់គ្នីគ្នាដើររកម៉ូដែល និងម៉ូដែន តែមិនទាន់បានដំណឹងអីសោះ ។ និយាយពីរឿងអាខ្មៅនោះវាជាបុគ្គលិកធ្លាប់ធ្វើការនៅក្រុមហ៊ុនរបស់បងដែរ តែដោយវាមានចរិតមិនល្អខិលខូចពេកត្រូវក្រុមហ៊ុនដេញឈប់អោយធ្វើការប៉ុន្មានខែហើយ ហេតុម៉េចបានជាវាបានដើរជាមួយកូនដែល និងកូនដែន ?

-ខ្ញុំក៏មិនដឹងដែររឿងនេះ ! ពីរសៀលនេះខ្ញុំបានទទួលទូរស័ព្ទរបស់ក្មួយម៉ូដែលប្រាប់ថាគេទៅតាមរកអាខ្មៅនៅឯជាយក្រុង តែខ្ញុំមិនដឹងថាជាយក្រុងម្តុំណាទេខ្ញុំបើកឡានដើររកអស់ចិត្តហើយមិនប្រទះពួកគេសោះ !។

-កូនដែលតាមរកអាខ្មៅនៅជាយក្រុង?(អ្នកស្រីឧទានដូចជានឹកឃើញអ្វីម្យ៉ាង) ប្រហែលជាពួកគេទៅផ្ទះអាខ្មៅហើយ ! ផ្ទះអាខ្មៅនៅម្តុំទំនប់ទួលគោក ម្តុំត្រឡោកបែកស្តីតែនោះបងមិនសូវស្គាល់ទេ លឺតែបុគ្គលិកធ្វើការក្រុមហ៊ុន គេនិយាយថាផ្ទះអាខ្មៅនៅជាយក្រុងម្តុំទួលគោកត្រឡោកបែក ! ការរៀបរាប់របស់អ្នកស្រីមីក្នុងទូរស័ព្ទទោះបីមិនបានបញ្ជាក់ពីលំនៅស្ថានរបស់អាខ្មៅច្បាស់លាស់ក៏ដោយក៏ជាពន្លឺមួយសំរាប់អោយនាយម៉េង និងសារ៉ាន់មានតម្រុយខ្លះ ក្នុងការស្វែងរកកូនប្រុសរបស់លោកសិរីភោគាដែរ ។

ម៉េងប្រញាប់បញ្ចប់ការសន្ទនាតាមទូរស័ព្ទ ហើយហៅចិនគិតលុយយ៉ាងឆាប់ ឯសារ៉ាន់ដើរទៅទះស្មាពូជិមដែលកំពុងរ៉ៃនៅរានលក់ស្រាថ្នាំ ។ ពូជិមដែល-ពាក់កណ្តាលជាពូជិម ពាក់កណ្តាលជាស្រាថ្នាំនោះមើលពីជើងម៉ាបែបហុទ្រមខ្លាំងល្មូក ហោចៅយកលុយអោយថ្លៃស្រានិងសាច់ក្លែមចេះតែខុសហោចៅ ឯគូកនជាមិត្តរួមផឹករបស់គាត់ទាំងពីរ បីនាក់នោះឃើញដូច្នោះក៏សើចទះតុទះជើងម៉ា រួចងើបយកស្រាមកតាមបង្អកពូជិមមួយក្អឹកពីរថែមទៀត ។សារ៉ាន់ទ្រាំមិនបានក៏ល្មូកហោចៅយកលុយ



ខ្លួនឯងចេញថ្លៃស្រា និងសាច់ក្លែមជំនួសពូជិមហើយអូសដៃគាត់ឡើងឡានដែលម៉េងបញ្ឆេះចាំជាស្រេច ។ ពូជិមប្រកែកមិនព្រមឡើងជិះឡានក្នុងកាប៊ីនខាងមុខជាមួយម៉េងនិងសារ៉ាន់ទេ គាត់ខំប្រតោងឡើងជិះកន្លែងដាក់ឥវ៉ាន់ខាងក្រោយវិញ ។ គាត់អុកគូថទៅវីពីរបីដងទំរាំឡើងរួច ។បានជាគាត់ជិះខាងក្រោយព្រោះគាត់ត្រូវការដេក ទម្លាប់គាត់តែស្រវឹងគឺគាត់ដេកហើយ ។ កន្លែងណាក៏គាត់ដេកបានដែរ ។

សារ៉ាន់ស្តីអោយពូជិមថា ៖

-នែ៎ពូ ! ពូឯងអួតថាមកជួយរកក្មួយបងម៉េងឥឡូវបែជាមកផឹកហើយដេកអត់បានការអីសោះ ! យកល្អត្រលប់ទៅផ្ទះពូឯងវិញទៅវាប្រសើរជាង !

-អញមិនខ្ចីទៅណាទេ ! អាណាថាអញស្រវឹង ? អញគ្រាន់តែងងុយដេកទេតើ !អញផឹកអញដើរអញដេកតែខ្លួនអញសោះមានពិបាកអោយគេបីគេពរអញពីកាលណា ? បើអញផឹកអោយគេបីគេសែងផឹកធ្វើអី ?....

ពូជិមនិយាយហើយ ក៏ទាញក្រណាត់តង់កៅស៊ូដំបូលឡានយកមកគ្របលើខ្លួនគាត់ហើយត្បុលដេកក្រវៀនៗទៅហោង ។

សារ៉ាន់ទាល់ប្រាជ្ញនឹកហួសចិត្ត ដើរមកបើកទ្វារឡានឡើងអង្គុយខាងមុខជាមួយនាយម៉េង ។ ម៉េងបញ្ជារថយន្តបោះពួយសំដៅម្តុំត្រឡោកបែក....។

ទួលគោកតំបន់ដែលមានភូមិសាស្ត្រខុសប្លែកពីតំបន់នានាក្នុងក្រុងភ្នំពេញដោយសារផ្លូវថ្នល់បែបក្រឡាជាសំបុកពីងពាង ដោយយកបង្គោលរង់តែនទូរទស្សន៍បីខ្ពស់ទទុងមួយជាចំណុចប្រសព្វ ។ អ្នកដែលមិនធ្លាប់ចេញចូលតំបន់នោះ ពេលចូលទៅរកមិត្តភក្តិឬបងប្អូនដែលមានលំនៅស្ថានក្នុងតំបន់នេះ ច្រើនមានការច្រឡំផ្លូវឬវង្វេង ។

ទួលគោកសំបូរទៅដោយផ្ទះវីឡាធំតូចជាច្រើន ដែលភាគច្រើនបានសង់នៅសម័យសាធារណរដ្ឋខ្មែរ លន់ណុល ។ប៉ុន្តែឆ្លងកាត់សម័យប៉ុលពតវីឡាតូចធំទាំងនោះត្រូវបានបោះបង់ចោលពុំមានការថែទាំដោយសារម្ចាស់ផ្ទះបានស្លាប់ក្នុងសម័យប៉ុលពតឬចាកចេញទៅបរទេស ។

ទើបតែក្រោយថ្ងៃ ៧ មករា ១៩៧៩ ទើបបានទួលគោកមានប្រជាជនចូលមករស់នៅវិញ ។

ប៉ុន្តែទោះបីជាប្រជាជាបានចូលមករស់នៅ សឹងតែគ្រប់លំនៅដ្ឋានទាំងនោះហើយក្តី ក៏មានភូមិគ្រឹះធំៗខ្លះស្ថិតនៅជាទីស្ងប់ស្ងាត់អាថ៌កំបាំង ។ ភូមិគ្រឹះទាំងនោះច្រើនជាកម្មសិទ្ធិរបស់មន្ត្រីឬអ្នកមានទ្រព្យសម្បត្តិ ។ ផ្ទះខ្លះក៏ត្រូវបានគេជួលឬលក់បន្តយកចំណេញជាច្រើនម្ចាស់ច្រើនត ។ ក្នុងចំណោមភូមិគ្រឹះទាំងនោះមានភូមិគ្រឹះធំមួយស្ថិតនៅដាច់ឆ្ងាយពីគេ ដំបូលអើតខ្ពស់ផុតចុងឈើធំៗ ដែលមានស្រមោលខ្មៅទទុងបង្ហាញរាងគួរស្ញើមក្នុងរាត្រីកាល ។ ផ្នែកខាងក្រៅជុំវិញវិមាន , មានកំផែងស៊ីម៉ង់ត៍ព័ទ្ធជុំវិញបំភ្លឺដោយអំពូលភ្លើងគោមពីរបី មានក្បាច់រចនាគួរអោយចង់គយគន់ ។ នៅមាត់ច្រកភូមិគ្រឹះនោះ បុរសម្នាក់អាយុប្រមាណ ៥០ឆ្នាំមាឧមាំសម្បុរខ្មៅកំពុងឈរជក់បារីយាមនៅមាត់ក្លោងទ្វារដែកភ្នែករំពៃមើលទៅសព្វគ្រប់ទិសទី.....។

មួយសន្ទុះក្រោយមកយុវជនពីរនាក់ដើរចេញ ពីក្នុងភូមិគ្រឹះមកជួបបុរសចំណាស់



នេះ ។ បុរសចំណាស់ក៏សួរទៅយុវជនសម្បុរខ្មៅនោះថា ៖

_អាខ្មៅ !ម៉េចទៅអាពីរនាក់បងប្អូននោះពួកឯងចាត់ការយ៉ាងណាទៅហើយ?

នាយខ្មៅតបទៅបុរសនោះវិញថា ៖

_ពូក្លឹងអើយ ! គំរោងការរបស់យើងកំពុងដំណើរការល្អ ខ្ញុំរៀបនិងបង្ក្រាបអាពីរនាក់បងប្អូននោះបានជោគជ័យទៅហើយស្រាប់តែបងរាមមកបញ្ជាអោយខ្ញុំប្រគល់កាំភ្លើងអោយអាម៉ូដែលវិញ !

បុរសចាស់ឮថាកាំភ្លើងត្រូវធ្លាក់ក្នុងដៃម៉ូដែលវិញក៏បង្ខំសួរថា ៖

_ថាម៉េច !អាម៉ូដែលយកកាំភ្លើងនោះទៅវិញហើយ ! វីវរហើយផែនការយើងត្រូវអនុវត្តនៅថ្ងៃស្អែកបានអាវុធឯណាប្រើ ?....

-ខ្ញុំតូចចិត្តណាស់ ! ( នាយខ្មៅនិយាយបណ្តើរ យកក្រដាសអនាម័យជូតមាត់វានិងជូតធ្មេញវាដែលហើមបណ្តើរ)

_បងរាមមិនគ្រាន់តែអោយខ្ញុំប្រគល់កាំភ្លើងអោយអាម៉ូដែលទេគាត់ថែមទាំងបង្គាប់អោយអាពីរនាក់បងប្អូននោះ វាយទាត់ធាក់ខ្ញុំចង់បាក់ចង្កេះថែមទៀត !។

_យី ! វាយ៉ាងម៉េចបានជាក្មួយរាមធ្វើដូច្នេះ ? ( បុរសឈ្មោះក្លឹងឧទានដោយភ្ញៀងឆ្ងល់)។

_ខ្ញុំស៊ីយដល់ហើយថ្ងៃនេះ ( អាខ្មៅនិយាយដោយអួលបំពង់ក) កាលនៅគៀនស្វាយត្រូវគេដាល់បាក់ធ្មេញអស់មួយ ។ ឥឡូវមកដល់ទីនេះត្រូវអាពីរនាក់បងប្អូនវាយតាមចិត្តទៀត ។( ពោលហើយអាខ្មៅលូកហោប៉ៅអាវយកកន្សែងដែលរុំធ្មេញវាដែលបាក់នោះមកលាបង្ហាញពូក្លឹង)។

_មិនអីទេឡើងហ្នឹង !ចាំអញទៅសួរក្មួយរាមមើលហេតុអីបានជាបង្គាប់អោយ

គេវាយអាខ្មៅក្លួយអញទ្រមខ្លួនដល់ម្លឹង ?ប៉ុន្តែមុននិងទៅសួរក្លួយរាមអញត្រូវដឹងសាច់រឿងឯងហ្វហែតាំងពីព្រឹកមកខ្លះៗព្រោះវាមិនដែលទទេៗក្លួយរាមអោយអាក្ដែនអាក្ដែលវាយឯង ?( ពូក្លឹងនិយាយបណ្ដើរសម្លឹងដោយទឹកមុខមាំទៅកាន់ផ្ទះធំ រួចគាត់ដឹកដៃអាខ្មៅនិងអាស៊ើទៅអង្គុយលើបង់ថ្មក្បែរកូនផ្ទះរបស់គាត់ជិតរបងនៃវិមាន ដែលនៅទីនោះមានម៉ូតូបួនគ្រឿងចតចោលប្រឡាក់ភក់ស្រម៉ក់មើលមិនយល់)។

ពេលអង្គុយស្រួលបួលហើយពូក្លឹងសួរទៅអាខ្មៅថា ៖

- មើលអាខ្មៅនិងអាស៊ើ ! ឯងរៀបរាប់ប្រាប់អញមកមើលរឿងរ៉ាវយ៉ាងម៉េចខ្លះបានជាដល់ថ្នាក់ប្រកាប់ប្រចាក់គ្នាបាក់ធ្មេញអស់១ដូច្នេះ?( ពូក្លឹងតឿនអោយអាខ្មៅនិងអាស៊ើនិយាយរឿងរបស់ខ្លួនប្រាប់គាត់)។

អាខ្មៅវានិយាយរៀបរាប់មិនកើត ព្រោះវារហឹមមាត់និងឈឺកន្លែងធ្មេញបាក់ក៏អោយអាស៊ើអ្នកនិយាយតាមសាច់រឿងហ្វហែអោយពូក្លឹងស្ដាប់ ។

អាស៊ើមាត់ល្អិតតែបានសំដី ក៏ចាប់ផ្ដើមរៀបរាប់ តាំងពីក្រុមវាជិះម៉ូតូទៅលេងកៀនស្វាយឃើញនាងសូណេតមានរូបឆោមលោមព័ណ៌ល្អត្រចៀកបេតី ។ នាយរាមក៏ដាក់ផែនការអោយវាពីរនាក់បង្កហេតុចាប់នាងសូណេតដាក់ម៉ូតូ។តែផែនការវាត្រូវបរាជ័យព្រោះសារ៉ាន់និងម៉េងមកជួយរំដោះនាងសូណេតទាន់ ។ វានិយាយពីឆាកប្រយុទ្ធរវាងក្រុមវាជាមួយនាយម៉េង និងសារ៉ាន់ដោយធ្វើកាយវិការទៅតាមសាច់រឿង វាឆ្លៀតបញ្ជាក់គ្រង់រឿងអាស៊ើត្រូវមីងសុតលេចនោមដាក់ និងនាយម៉េងវាយអាខ្មៅបាក់ធ្មេញអស់មួយ វានិយាយហើយស្ទុះទៅកញ្ឆក់ធ្មេញពីដៃអាខ្មៅ ហុចទៅអោយពូក្លឹងមើល ពូក្លឹងឃើញធ្មេញរបស់អាខ្មៅមានជង្គរស៊ីកញ្ឆតផង និងឃើញកាយវិការក្រម៉ាច់ក្រម៉ើម ដៃខ្វិជើងខ្វិរបស់អាស៊ើផងក៏អស់សំណើចលឺសូរឃឹសៗ ។



ឯអាខ្មៅឃើញពូខ្វិងសើចលឺឃឹសៗ វាទ្រាំសើចក្នុងពោះមិនបានក៏ផ្ទាយសំណើចមកខាងក្រៅ យុំសៗដែរបណ្ដាលអោយឈឺធ្មេញក៏ប្រែមុខជូរវិញ ។

អាស៊ើរៀបរាប់បន្តទៀតថា ៖

ក្រោយពេលដែលក្រុមវាបរាជ័យយ៉ាងជូចត់នៅកៀនស្វាយហើយ វាក៏ឡើងបើកម៉ូតូនាយរាម ជិះពីក្រោយ , ឯអាខ្មៅជិះម៉ូតូវីវ៉ារបស់វាបោះពួយយ៉ាងលឿនចាកចេញពីកៀនស្វាយសំដៅមកភ្នំពេញ ។ មួយសន្ទុះទើបឃើញម៉ូតូ ម៉ូដែល និងម៉ូដែនតាមពីក្រោយយ៉ាងលឿន ។

នាយស៊ើបើកម៉ូតូព្រហើនណាស់ ទោះវាមានមាឌតូចដៃខ្វិជើងខ្វិតែវាអាចបើកជ្រែម៉ូតូស៊ីក្លូឡានទាំងអស់កំពុងចរាចរតាមបណ្ដោយផ្លូវ ។ឯអាខ្មៅក៏មិនអន់ដែរទោះបីមានឧបសគ្គយ៉ាងណាឬរំខានអ្នកណាក៏ដោយក៏នាយជើងល្អមិនសូវបន្ថយល្បឿនដែរ។ រឿងច្បាប់ចរាចរមិនបាច់យកទៅនិយាយអោយនាយខ្មៅ និង នាយស៊ើស្ដាប់ឡើយ ។ នេះហើយដែលគេហៅថាក្មេងឈាមរាវ មិនទាន់ឃើញភ្ការឃ្លួសវាមិនទាន់ជឿថាក្នុងលោកនេះមានសេចក្ដីស្លាប់ទេ ។

ពួកគេបានឆ្លងផុតស្ពានច្បារអំពៅ ក្រឡេកឃើញម៉ូតូម៉ូដែល និងម៉ូដែនតាមប្រកិតៗពីក្រោយ អាខ្មៅក៏បន្ថែមល្បឿនតាមផ្លូវមុនីវង្សឆ្ពោះទៅជើង ។ អាស៊ើដែលឌុបនាយរាមពីក្រោយប្រែនតាមដែរ ។

នគរបាល ពីរបីនាក់ដែលឈរយាមនៅគោលដៅរង្វង់មូលខាងលិចស្ពានច្បារអំពៅលើកដៃរាឃាត់ម៉ូតូសាហាវៗទាំងនេះដើម្បីយកមកអប់រំណែនាំអោយគោរពច្បាប់ចរាចរ ឬក៏ផាកពិន័យព្រោះជិះម៉ូតូលើសល្បឿនកំណត់ក្នុងទីក្រុង ។ តែមានឃាត់បានឯណា ?។

មកដល់ស្តុបបួកគោក្រុមអាខ្មៅក៏បត់ទៅខាងលិចតាមផ្លូវម៉ៅសេទុង ឯម៉ូដែល និងម៉ូដែនមកដល់ស្តុបបួកគោ ម៉ូតូម៉ូដែនអស់សាំងក៏ចូលចាក់សាំងនៅហ្គារាសបួកគោនោះទៅ ។

អាខ្មៅនិងអាតឿគិតតែបោះពួយទៅមុខស្មានថាម៉ូដែលនិងម៉ូដែនតាមពីក្រោយ។ អាខ្មៅគិតក្នុងគំនិតវាថា បើទុកកាំភ្លើងនិងខ្លួនវាក្រែងអាម៉ូដែលមកទារយកទៅវិញក៏ហុចកាំភ្លើងទៅនាយរាមអោយទុកចុះចំណែកវាចាំដោះសារជាមួយម៉ូដែលជាក្រោយ។

នាយរាមទទួលកាំភ្លើងពីអាខ្មៅក៏សៀតទុកនៅចង្កេះខោហើយបែកផ្លូវគ្នាដោយសន្មត់ថាជួបគ្នានៅវិទ្យាទួលគោក ។ អាខ្មៅប្រគល់កាំភ្លើងអោយនាយរាមរួចហើយវាងាកមើលក្រោយស្រាប់តែបាត់មិនឃើញម៉ូតូម៉ូដែល និង ម៉ូដែនតាមពីក្រោយក៏ត្រឡប់ក្រោយតាមរកមើលពួកម៉ាកវាក្រែងមានគ្រោះអាសន្នអីបានជាបាត់មិនឃើញស្រមោលដូច្នេះ ។

បន្តិចមកម៉ូតូបងប្អូនទាំងពីរចាក់សាំងរួចរាល់ហើយ ក៏ចេញពីហាងសាំងជួបវ៉ាក់និងអាខ្មៅ ។ ម៉ូដែលស្រែកទារកាំភ្លើងពីអាខ្មៅ ៖

-អាខ្មៅឯណាកាំភ្លើងអញ ?

នាយខ្មៅលឺនាយម៉ូដែលទារកាំភ្លើង ក៏ប្រែនម៉ូតូគេចចេញទៅភ្លាមអត់និយាយតមួយម៉ាត់ឡើយ ។ នាយម៉ូដែលបញ្ឆាម៉ូតូហោះតាមភ្លាមទាំងមុខក្រហមដូចភ្លើង ។

ការប្រដេញតាមគ្នាដ៏សាហាវ ចាប់ផ្តើមក្រោមស្បែរោយរាយនៃព្រះពិរុណ ។

ម៉ូតូទាំងបីគ្រឿងប្រដេញគ្នាវក់វីតាមផ្លូវទាំងឡាយនៃទីក្រុង ទីបំផុតអាខ្មៅបានទៅដល់ផ្ទះវានៅត្រឡោកបែកជិតថ្នល់រថភ្លើង ។ វាណាតចោលម៉ូតូរត់ទៅពួនក្នុងផ្ទះវា ។ផ្ទះរបស់អាខ្មៅជញ្ជាំងធ្វើអំពីក្តារឡាំងនិងកុងបាកេចាស់ ដំបូលប្រក់ស្លឹកមានចែកជាបន្ទប់តូចៗសំរាប់ជួលអោយភ្ញៀវស្នាក់នៅម្តងម្កាល ។ ផ្ទះនោះសង់ពីឈើទីកស្អុយម្ខាងនិងទីទួលម្ខាងជាប់និងថ្នល់រថភ្លើង ។ បើចង់ចូលទៅផ្ទះអាខ្មៅគេត្រូវដើរតាមស្ពានឈើតូចមួយញ័រទ្រើតៗ ទាញទាំងផ្ទះនោះអោយញ័រផងដែរ ព្រោះសសរផ្ទះធ្វើអំពីកូនឈើតូចៗ ដាំក្នុងទឹកភក់មិនបានគុណភាពទេ ។ ផ្ទះនៅម្តុំផ្ទះអាខ្មៅសង់ជាប់គ្នារើកមានស្ថានភាពដូចៗគ្នា ។

នាយម៉ូដែលតាមនាយខ្មៅទៅដល់ផ្ទះនោះ ក៏ចតម៉ូតូទុកអោយម៉ូដែនជាប្អូនមើលម៉ូតូ ឯខ្លួនឯងដើរតាមស្ពានទៅមាត់ទ្វារផ្ទះអាខ្មៅ ឃើញទ្វារបិតជិតក៏ស្រែកហៅអាខ្មៅ ៖

-អាខ្មៅបើកទ្វាអោយឆាប់ !

-អញមិនបើកទេ ! ឯងមានការអីនិយាយមក !

-ឯងកុំធ្វើពើអាខ្មៅ ! អោយកាំភ្លើងមកអញវិញអោយឆាប់បើចង់សុខខ្លួន ! (ម៉ូដែលសំឡុតអាខ្មៅ )

-ឯងចង់បានកាំភ្លើងវិញ ម៉េចមិននិយាយគ្នាអោយស្រួលទៅចាំបាច់ខឹងអីដល់ម្លឹង ! សុទ្ធតែមិត្តភ័ក្តយើងទេតើ !(អាខ្មៅនិយាយទន់ភ្លន់បន្លន់ចិត្តម៉ូដែល)

-កុំបាច់សំដីផ្អែមដាក់អញអាខ្មៅ ! បើកទ្វារអោយឆាប់អាគំរក់ ថ្លើមធំណាស់ហ៊ានបាញ់ពួអញ !ថ្ងៃនេះអញប្រដៅឯងអោយដឹងម្តង!(និយាយហើយម៉ូដែលធាក់ទ្វារគ្រាំងៗ) ឯងយកកាំភ្លើងអញទៅលាក់ឯណាអោយភ្លាមមក !។

-អាម៉ូដែល ! អញនិយាយល្អដាក់ឯង,ឯងមិនចេះស្តាប់ទេឬ ?បើឯងចិត្តសៀងចូលមកយកទៅ ! ប៉ុន្តែកុំថាអញមិនចេះឃោគយល់មិត្តភិក្តណាំ ! អញតែថាបាញ់គឺ

គឺបាញ់ហើយ ! ឯងដឹងអញស្រាប់ហើយ ! បើចង់ងាប់ចូលមក !។(នាយខ្មៅនិយាយគំរាមម៉ូដែល ហើយយកដែកមួយនៅក្បែរខ្លួនមកកោសនិងរនុកទ្វារធ្វើក្រាកៗដូចជាអារមេកាំភ្លើង) ឯងកុំចូលជីយប្រយ័ត្នអញបាញ់!(នាយខ្មៅនិយាយធ្វើឬកគ្រាន់ដូចជាខ្លួនកំពុងកាន់កាំភ្លើង តែតាមការពិតកាំភ្លើងនោះត្រូវបាននាយប្រគល់អោយនាយរាមបាត់ទៅហើយ)។

ម៉ូដែលកំហឹងឡើងដល់កំរិតហើយ មិនអាចទ្រាំបានតទៅទៀតក៏បុកទម្លាយទ្វារគ្រាំង ទ្វារក៏របើកឡើងផ្អើលដល់ភ្ញៀវប្រុសស្រីមួយចំនួនបែកសំបុកប្រសេចប្រសាចរត់ចេញពីបន្ទប់តូចៗនោះ ខ្លះភ្លេចស្លៀកខោខ្លះរបូតក្រមាឯនារីខ្លះស្រែកយ៉ៃព្រោះភ័យលឺនាយខ្មៅថាមានកាំភ្លើង ។ ពេលនោះម៉ូដែលស្ទុះហក់ទៅដាល់នាយខ្មៅផាច់ចំកន្លែងផ្កាមដែលហើមស្រាប់ ។ នាយខ្មៅស្រែករ៉ូយ !

-អាងាប់វាយអញឈឺម្ល៉េះ ! កន្លែងហ្នឹងច្រើញអញបាក់ស្រាប់ផង !វាយម៉េចមិនមើលកន្លែងផ្សេង ?!

នាយខ្មៅខឹងឡើងមុខរឹតតែខ្មៅទៅទៀត វាយាជើងធាក់ម៉ូដែល ១ជើងវិញ ។ ម៉ូដែលបោកចំបាប់ជាមួយអាខ្មៅឡើងញ័ររង្គើផ្ទះចង់រលំ ។

គូប្រយុទ្ធសុទ្ធតែពេញស្លាវកម្លាំងដូចដីរ ចុះប្រេងទាត់ធាក់ផ្ការមួលទៅប៉ះជញ្ជាំងប្រាវ ធ្លាក់ទាំងពីរនាក់កប់ក្នុងភក់ ស្មុយគគ្រុកផ្អើលសត្វមូសរុយ មមង់មម្យៀចហើរព្រាងព្រាត ។ មិនទាន់អស់ចិត្តទេ គេនាំគ្នាឡើងមកឈឺទូលវាយគ្នាទៀត ។ពេលនោះកាខ្វាន់ឪពុកនាយខ្មៅទើបមកពីរកទឹកដើម្បីយកមកចាក់បំពេញក្នុងក្លូនពាងតូចៗសំរាបភ្ញៀវក្នុងបន្ទប់ពិសេស ។គាត់ឃើញកូនគាត់វាយគ្នានឹងឃើញផ្ទះគាត់ទ្រេតធ្លាយជញ្ជាំងរាងគាត់ដាក់អម្រែកចុះ ស្ទុះមកមើលយំផងស្រែកផងថា ៖





-ស្លាប់ហើយ ! បាក់ផ្ទះអញអស់ហើយអាតិរច្ឆានោ ! អាកូនអប្រិយ ! បើចង់យគ្នា ម៉េចមិនទៅវាយនៅកណ្តាលស្តាតអូឡាំពិកទៅ !មកវាយគ្នាអីឈើផ្ទះអញ ! វាយបាក់ផ្ទះអញអស់ !ព្រះម្ចាស់ថ្លៃអើយជួយមើលចុះ ផ្ទះខ្ញុំខំសង់ចង់ងាប់ទំរាំបាន

វាអត់ជួយខ្ញុំ១រៀលសោះ មកបំផ្លាញផ្ទះខ្ញុំទៀត !លោកអើយលោក ! តើខ្ញុំបានអីរកស៊ីសព្វថ្ងៃបានផ្ទះហ្នឹងហើយសំរាប់ដាក់ម៉ូយ ម៉្ងៃពីរបីនាក់គ្រាន់បានលុយទិញអង្ករស្ងោរឥឡូវពួកអាប្រែតពីរនាក់នេះវាមកបំផ្លាញខ្ញុំហិនហោចអស់ហើយ !។

តាខ្នាន់ស្រែកទ្រហោយំ ទាល់តែផ្អើលអ្នកជិតខាងមកមើលអ៊ូ ។ អ្នកខ្លះជួយចាប់គូប្រយុទ្ធទាំងពីរដែលកំពុងបោកចំបាប់ដាល់តប់គ្នាប្រឡាក់ភក់ស្រមឹក ។ តែអ្នកទាំងពីរនៅតែរើបំរះទៅវាយគ្នាទៀត ។

តាខ្នាន់ស្ទុះទៅកន្ត្រាក់ដងរែក ដេញវាយនាយខ្មៅត្រូវកំប៉េះគូថមួយដងរែកភ្ញស !។នាយខ្មៅស្ទាងចុះប្រេងក្រឡេកឃើញឪវាយាដងរែកបំរុងដាក់ថែមមួយទៀតអាជើងល្អរត់ភឹងទៅទាញម៉ូតូបញ្ឆេះរត់ទៅបាត់ស្រមោល ។ ឯនាយម៉ូដែលត្រូវអាខ្មៅវាយហើមមុខហើមមាត់គួរសមដែរ ថែមត្រូវមួយដងរែកតាខ្នាន់ទៀត ចំកំប៉េះគូថដូចអាខ្មៅដែរ ដើរផ្អៀងខ្លួនបែហុទ្រមគួរសមដែរ ។តាខ្នាន់មិនបានដេញវាយទៀតទេព្រោះម៉ូដែលមិនមែនកូនចៅគាត់ ។ ឯម៉ូដែលមិនខឹងសម្បារជាមួយតាខ្នាន់ដែរ ព្រោះនាយក៏បានរួមចំណែកធ្វើអោយបាក់បែកផ្ទះតាខ្នាន់ដែរ ។

ម៉ូដែលប្រញាប់នាំប្អូនជិះម៉ូតូដេញតាមអាខ្មៅ...។

និយាយពីនាយរាមនិងអាតឿម្តង .ពេលបែកពីអាខ្មៅមកនាយរាមប្រាប់អាតឿអោយប្រញាប់ទៅវីឡាទួលគោក ព្រោះម៉ោង ៣រសៀលហើយ ពុំទាន់ហូបបាយថ្ងៃត្រង់នៅឡើយ ។

ចូលដល់ភូមិគ្រឹះទួលគោកកាលណានាយរាមនិងអាតឿឡើងទៅបន្ទប់បាយជាន់ទី១ ឃើញមីងម៉ាប់រៀបចំបាយទឹកទុកហើយស្រេច ។ អាតឿស្ទុះផ្កួតទៅអង្គុយនៅតុបាយ . នាយរាមឃាត់ថា ៖



_អាតឿ ! ឈប់សិន ! ចាំគ្នាយើងមកគ្រប់គ្នាសិន !

_ចាំពួកវា ? ល្អើយមិនដឹងថ្មើរណាវាមកទេ ! ពេលនេះបែបវាកំពុងប្រកាប់ប្រចាក់គ្នាដេកពេទ្យខ្លះហើយក៏មិនដឹង!(នាយតឿនិយាយរួចហើយដើរថយក្រោយបន្តិចពីតុបាយតែភ្នែកសំឡឹងភ្លៅមាន់ក្នុងចាន .គ្រាន់តែនាយរាមបែក្រោយបន្តិចនាយលូកដៃទាញភ្លៅមាន់លាក់ក្រោយខ្នងធ្វើហី ។

មីងម៉ាប់ឈរក្បែរនោះឃើញដូច្នេះក៏ធ្វើជាក្អកគ្រហែម......នាយរាមអង្គុយចុះទៅលើកៅអីសាឡុងដកកាំភ្លើងពីចង្កេះមកកាន់ ផ្ទៀងផ្ទង់មើលកាំភ្លើងហើយអាវមេលីក្រាក ធ្វើអោយនាងម៉ាប់អ្នកធ្វើបាយដែលមានខ្លួនមូលប៉ុនចាំវឈរក្បែរនោះភ្ញាក់សម្លឹងមកនាយរាម ។ នាយរាមបែកាំភ្លើងតម្រង់មីងម៉ាប់ . មីងម៉ាប់ភ័យស្លាំងមុខយកដៃវាឃាត់ថា ៖

-កូយរាមកុំលេងអីចឹងមីងភ័យណាស់ មីងខ្លាចកាំភ្លើងណាស់ !។

នាយរាមក៏បង្វែចុងកាណុងកាំភ្លើងទៅរកអាតឿម្តងអាតឿភ្ញាក់បើកភ្នែកមូលៗប៉ុនប្រាក់កាក់ហាមាត់ជង្គ្រង់ធ្លាក់ជើងមាន់ពីមាត់ក្តុកទៅដី(វាលួចស៊ីជើងមាន់)។

-អាក្បត់ ! ហ៊ានលួចស៊ីម្ហូបមុនគេមុនឯងផងឬ ? ឯងស្មានថាអញភ្លើមិនដឹងឯងលួចស៊ីឬ ? ខ្ជាក់សាច់មាន់ចេញអោយអស់ពីក្នុងមាត់ឯងភ្លាមមក ! កុំអោយអញបាញ់ឯងបែកក្បាលទាន់អាចោរម្សៀត ! វាមិនដែលងាប់អត់បាយមួយពេលនោះទេ !

នាយតឿអោនមុខខ្ជាក់សាច់មាន់ចេញពីមាត់ហើយដើរអោនៗចូលបន្ទប់ទឹកបាត់ទៅ

រំពេចនោះទូរស័ព្ទដៃរបស់នាយរាមបន្លឺឡើង...នាយរាមលើកទូរស័ព្ទមកស្តាប់ស្គាល់ច្បាស់ជាសម្លេងចាំរបស់គេកំពុងនិយាយ ៖

-អាឡូ ! កូនរាម ! ឯងកំពុងស្ថិតទៅទីណា ?





-បាទប៉ា ខ្ញុំនៅផ្ទះទួលគោក !

-ព្រឹមមិញឯងទៅណាខ្លះ ?

-បាទប៉ាខ្ញុំមានទៅណា ! ខ្ញុំទៅសាលា មកពីសាលាចូលផ្ទះហ្នឹង !

-និយាយកុហក ! ប៉ាខំទុកចិត្តឯងថាអោយមកនៅចាំផ្ទះទួលគោកនេះ ឯងបែជានាំពួកម៉ាកដើរលេងធ្វើផ្តេសផ្តាស ។អម្បាញ់មិញលោកស្នងការនគរបាលប្រាប់អញអស់ហើយ ថាឯងបានទៅចាប់កូនក្រមុំគេនៅតៀនស្វាយ ! ហើយបង្កឿងរាវវ៉ាយតប៉គ្នានៅទីនោះទៀត ។ឯងកុំស្មានថាឯងធ្វើអីនគរបាលគេមិនដឹង ! គេយល់ដល់អញជាឪឯងកុំអីឯងនិងពួកម៉ាកឯងក៏មិនសុខខ្លួនដែរ ! នគរមានច្បាប់ណាកូន !កុំធ្វើផ្តេសផ្តាស ។ ម្យ៉ាងទៀតឯងកុហកប៉ាថាទៅរៀនមហាវិទ្យាល័យរាល់ថ្ងៃតែខាងសាលាគេប្រាប់ប៉ាថាឯងចូលសាលា ១អាទិត្យបាត់១ខែ តើដូចគេប្រាប់ប៉ាមែនទេ ?

-អត់ទេប៉ា កុំជឿលោកគ្រូចេះតែថាហ្នឹង ! ខ្ញុំទៅរៀនរាល់ថ្ងៃតើ !

-នៅផ្លៀតប្រកែកទៀត ! អាកូនចោលម្សៀតនេះ ! អញឆ្ងល់ដល់ហើយរ៉ុយឯងកាត់ពូជទៅណាក៏ខូចម្ល៉េះ ? ប្រដៅមិនស្តាប់សោះ នែ៎អញប្រាប់អោយហើយណាបើមិនកែគំនិតខូចចោលទេ អញនិងបញ្ជូនឯងទៅនៅស្រុកបារាំងជាមួយពូឯងហើយដឹយ !

-ប៉ាចេះតែជេរខ្ញុំហើយ !ខ្ញុំមានកាត់ពូជទៅខាងណាកាត់ទៅប៉ាឯងហ្នឹង!ប៉ាចង់អោយខ្ញុំទៅនៅស្រុកបារាំងជាមួយពូរឹតតែស្រួលទៀតប៉ា !ពូស្រឡាញ់ខ្ញុំជាងប៉ាផង !

-អើ !ល្អហើយ !ទៅនៅស្រុកបារាំងសាកមើលទៅអាកូន ! ឬកដូចឯងបើមិនវាប់ខ្មោះទាំងថ្ងៃថែស ! ប៉ូលីសបារាំងវាមិនដែលឃោតយល់ឯង ឬស្គាល់ឯងជាកូនញទេ ! អញឃើញខ្មោះដៃព្យរណោងនៅចង្កេះខោប៉ូលីសបារាំង កុំសូវជេរជាមួយ

ប៉ូលីសស្រុកគេអានាងអើយ ! តែជាប់ខ្នោះគឺជាប់ហើយ កូនកុម្ប៉ីយក៏ដោយអោយតែធ្វើខុសច្បាប់ ។ អើនិយាយអីចឹង ស្អែកម៉ោង១២ថ្ងៃត្រង់ឯងទៅទទួលពូឯងមកពីស្រុកបារាំងនៅចំណតយន្តហោះពោធិ៍ចិនតុងផងណាំ !។

-ថាម៉េចប៉ា ? ពូមកពីស្រុកបារាំង ? គាត់មកធ្វើអីប៉ា ?

-ឯងភ្ញាក់ផ្អើលអី ?ក្រែងឯងថាចង់ទៅនៅស្រុកបារាំងជាមួយពូឯងឬ ?ឥឡូវពូឯងមកហើយ ! ឯងទៅទទួលគាត់ផងណាំ !

-ដឹងស្អីទេប៉ានៅសុខៗស្រាប់តែនឹកឃើញចង់បញ្ជូនខ្ញុំទៅនៅស្រុកបារាំងឯណាទៅវិញ(នាយរាមរអ៊ូតិចៗ)

-ឯងនិយាយស្អីតិចៗអញស្តាប់មិនបាន ? កុំភ្លេចណាំស្អែកម៉ោង ១២ទៅទទួលពូឯងនៅពោធិ៍ចិនតុង ! ឮទេ !។

-បាទប៉ា

នាយរាមទើបនិងដាក់ទូរស័ព្ទចុះ....ស្រាប់តែអាខ្មៅម៉ូដែលម៉ូដែនរត់ប្រដេញគ្នាឡើងតាមជណ្តើរមកដល់ហត់គឃ្លូរ ខោអាវប្រឡាក់ភក់ស្អុយពេញបន្ទប់ ។

នាយរាមស្រែកឃាត់គូប្រយុទ្ធទាំងពីរអោយឈប់ប្រខាំគ្នា ។

-បានហើយៗ !! ឈប់ច្បាំងគ្នា ! សន្តិភាព !សន្តិភាព !ថាហើយរាមទាញអាខ្មៅទៅម្ខាង ទាញម៉ូដែលទៅម្ខាងទៀត ។ ម៉ូដែលចង្អុលអាខ្មៅហើយពោលថា ៖

-បងរាមកុំឃាត់ ទុកអោយខ្ញុំវាយអាក្បាលខូចហ្នឹង ! វាយកកាំភ្លើងទៅបាញ់មាខ្ញុំហើយយកកាំភ្លើងនោះទៅលាក់ទុកឯណាបាត់ !

នាយខ្មៅចង្អុលមុខម៉ូដែលវិញហើយតបថា ៖

-បងរាមមើលចុះ អាកាដែលហ្នឹងមេរករឿងណាស់ ! ត្រង់មាវាវាយខ្ញុំបាក់



ធ្មេញរស់មួយ(នាយខ្មៅពោលហើយ ថែមទាំងលូកហោប៉ៅអាវយកកូនកន្សែងដែលរុំធ្មេញបាក់ចេញមកលាបង្ហាញម៉ូដែល) ឃើញទេ ! នេះនែ៎ធ្មេញអញ !ដែលបាក់ដោយស្នាដៃពូរបស់ឯង ! ឯចំណែកកាំភ្លើងឯងអញបានប្រគល់អោយបងរាមហើយ !

-ឥឡូវឈប់ ! ឈប់វាយគ្នាសិន(នាយរាមឃាត់អ្នកទាំងពីរ)ទុកអោយយើងដោះស្រាយអោយ !មិនអីទេរឿងកាំភ្លើងនេះខ្ញុំជាអ្នករារាំងគាត់ទៅចុះ !ហ៎ានេះកាំភ្លើង! (នាយរាមដកកាំភ្លើងពីចង្កេះបង្ហាញម៉ូដែលហើយដកហ្វូតបង់គ្រាប់ចេញរួចប្រគល់តួកាំភ្លើងអត់គ្រាប់នោះទៅអាខ្មៅ) អាខ្មៅ ! អញមានលក្ខខណ្ឌ ៣យ៉ាងដើម្បីដោះស្រាយបញ្ចប់ជម្លោះនេះ

-ទី១ ចូរអាខ្មៅឯងយកកាំភ្លើងនេះប្រគល់អោយម៉ូដែលវិញភ្លាម !(ថាហើយនាយរាមប្រគល់កាំភ្លើងអោយអាខ្មៅហើយ រុញអាខ្មៅអោយយកកាំភ្លើងនោះទៅអោយម៉ូដែល) នាយខ្មៅក៏កាន់កាំភ្លើងទាំងទើសទាល់ទៅប្រគល់អោយម៉ូដែលវិញ ។

-ទី២ អាខ្មៅត្រូវឈរអោយស្ងៀមមួយកន្លែង ហើយម៉ូដែលនិងម៉ូដែនត្រូវទាត់អាខ្មៅ ១ជើងម្នាក់ដើម្បីជាថ្នូរចំពោះការដែលអាខ្មៅបានបាញ់ពូរបស់អ្នកទាំងពីរ ។ចាប់ផ្តើមទាត់ !

នាយម៉ូដែល និងម៉ូដែនចូលទៅទាត់នាយខ្មៅម្នាក់ ១ជើងនាយខ្មៅអុកតូទនៅគៀនជញ្ជាំងយំស្បែហៗដូចកូនក្មេង ។

-បានហើយ !( រាមឃាត់អ្នកទាត់ទាំងពីរ )

-ទី៣ ម៉ូដែល និងម៉ូដែនត្រូវទាញដៃអាខ្មៅអោយងើបឡើង ហើយអាខ្មៅត្រូវចាប់ដៃអ្នកទាំងពីរវិញសើចរកគ្នាទៅវិញទៅមកបញ្ចប់ជម្លោះ ! ហើយនាំគ្នាទៅកាន់បន្ទប់ទឹកផ្លាស់សម្លៀកបំពាក់ហូបបាយ....បន្ទាប់ពីហូបបាយរួចយប់បន្តិចយើងមានកម្ម

វិធីចូលរាំកំសាន្តនៅការ "រាត្រីស្ថានសួគ៌" ដើម្បីផ្លាស់ប្តូរអារម្មណ៍ថ្មី បំភ្លេចរឿងចាស់ ។

_មិនបាច់ទេ ! អញមើលខ្លួនឯងបានហើយ ! ទាត់អញចង់ប្រកាច់ហើយមកធ្វើឫកជាឯងជួយលើកអញបានហើយទៅ !អញមិនមែនកូនក្មេងអោយឯងវាយហើយលួងក្រោយនោះទេ !។(នាយខ្មៅពោលហើយដើរចូលបន្ទប់ទឹកមុជទឹកផ្លាស់ខោអាវរួចមិនខ្ចីស៊ីបាយ នាំអាតឿចុះជណ្តើរមកក្រោមជួបពូភ្លឹង ហើយសាច់រឿងបានបញ្ចប់ត្រឹមនេះ.....។

ពូភ្លឹងស្តាប់រឿងអាខ្មៅ និងអាតឿចប់ ក៏ងើបដើរចូលក្នុងបន្ទប់គាត់យកនំអន្សមធំៗពីរមកហុចអោយអាខ្មៅមួយអាតឿមួយ ៖

_ហ៎ ស៊ីនំអន្សមសិនទៅ ! ពួកឯងមិនស៊ីបាយប្រយ័ត្នខ្យល់ចាប់ ។គេវាយទ្រមខ្លួនហើយអត់ស៊ីបាយទៀតបើមិនអាណិតខ្លួនឯងទេក៏គួរអាណិតព្រូនក្នុងពោះឯងដែរ ។ស៊ីរួចអញមានការនិយាយជាមួយឯង ។

ពេលនោះមីងម៉ាប់បានលើកបាយមួយចានសមកអោយអាតឿ និង អាខ្មៅហូប ។នាយទាំងពីរចោលនំអន្សម ហើយហូបបាយវិញ ។ វាត្របាក់ដូចកូនជ្រូកដែលគេបង្អត់អាហារ ។

តាភ្លឹងមើលក្មេងទាំងពីរហើយសើចរួចពោលថា ៖

_បើពួកឯងឃ្លានម្ល៉េះៗ សម័យអាពតដាច់ពោះស្លាប់បាត់ទៅហើយ ! សម័យនោះកុំថាទៅដល់បាយសូម្បីតែមើមឈើក៏រកមកដាក់ក្នុងក្រពះមិនបានដែរ ។ឥឡូវរឿងរ៉ាវរបស់ឯងសន្មត់ថាចប់សព្វគ្រប់ហើយ ព្រោះក្មួយរាមបានដោះស្រាយអោយហើយ !

ពូភ្លឹងអុចបារីជក់មួយទើបបន្តទៅទៀតថា ៖



_ឯងទាំងពីរនាក់ត្រូវចាកចេញទៅកំពង់ស្ពឺនៅព្រឹកស្អែកជាមួយអញ ។ យើងត្រូវទៅជួបប្អូនក្មួយនៅកំពង់ស្ពឺ គឺមានតែប្អូនក្មួយទេដែលដឹងកន្លែងលាក់កំណប់មាសនោះ ។ រឿងអ្វីចាំយើងនិយាយគ្នាពេលទៅដល់កំពង់ស្ពឺ ។

មីងម៉ាប់ដែលឈរនៅក្បែរនោះលឺថាគេនាំគ្នាទៅជីកកំណប់នៅកំពង់ស្ពឺក៏ល្វកសំដីទាំងមុខញញឹមញញែមថា ៖

_លោកបងភ្លឹង ! បើលោកបងជីកកំណប់បានចែកខ្ញុំខ្លះផងណាំ !

ពូភ្លឹងតបថា ៖

_អើមិនអីទេខ្លាប់ ! ចាំអញទិញខ្សែក្រទ្បុះគោអោយឯង ១ខ្សែ ហើយទៅណាមកណាមិនបាច់ពាក់ទេស្តាយតែម្តងទៅណាំ !

នាងម៉ាប់សំឡក់ពូភ្លឹងហើយញៀតៗដាក់ថា ៖

_ដឹងស្អីទេពូភ្លឹងនេះ ! លេងច្រើនដល់ហើយ ! អោយតែហ៊ានទិញក្រទ្បុះគោមកបើខ្ញុំមិនចាប់ជន្លេនដាក់លាយបាយអោយពូឯងហូបវិញ !

ពេលនោះការសន្ទនាក៏ត្រូវផ្អាក ព្រោះនាយរាមបាននាំម៉ូដែលម៉ូដែនមកដល់ ។ពួកគេស្លៀកពាក់យ៉ាងសង្ហារ.....

ទ្រនិចនាឡិការចង្អុលម៉ោង ៨ យប់ហើយ នាយរាមមានអារម្មណ៍រីករាយណាស់ ។ ពេលរាត្រីតែងនាំមកនូវគន្ធពិដោរនៃជីវិតដ៏ស្រស់បំព្រង ។សន្សើមរាត្រីគឺជាលំអងផ្កាធ្លាក់ពីឋានសួគ៌ ដែលគេត្រូវតែក្រេបយកមកទុកក្នុងបេះដូង ហើយបេះដូងយុវជនគ្មានស្នាមគ្មានពំណាសម្បុរនៃទុក្ខវេទនាឡើយ ។

នាយរាមក៏ដូចម៉ូដែលម៉ូដែនដែរ គេធ្វើឫកពារហាក់ដូចជាគ្មានកើតហេតុការណ៍អ្វីពីថ្ងៃសោះ ។ គេញញឹមគេដើរច្រៀងរាំហួចពេញសួនច្បារបន្តិចទៀតគេនិងលោតរាំ